CSC
ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានកាតូលិក

# អ្នកនាំសារ
The Messenger

កាសែតចេញផ្សាយប្រចាំខែ ឆ្នាំទី៣ ថ្ងៃទី០១-៣១ ខែតុលា ឆ្នាំ២០០៩ លក់តម្លៃ ១០០០រៀល តែប៉ុណ្ណោះ លេខ ២៦

## មាតិកា



អំណាននៅយុវជនខ្មែរកំពុងរីកចម្រើន ទំព័រ ៥



សារមន្ទីរជាតិ អភិរក្ស និងតាំងបង្ហាញវត្ថុមរតក... ទំព័រ ៩



មជ្ឈមណ្ឌលវប្បធម៌បារាំង... ទំព័រ ១៧

# កង្វះខាតឆ្មបនៅមាន ប៉ុន្តែអាចនឹងលុបបំបាត់នៅពេលខាងមុខ




ការសម្រាលបុត្រធីតាប្រកបដោយសុខភាពល្អ និងមានសុវត្ថិភាព គឺជាក្ដីប្រថ្នារបស់មាតាបិតាគ្រប់រូប។ ដើម្បីសម្រេចបាននូវបំណងនេះ សេវាកម្មខាងឆ្មបជំនាញ ការពិនិត្យ និងថែទាំសុខភាពត្រូវតែធ្វើឡើងដោយហ្មត់ចត់។ ប៉ុន្តែបញ្ហាឆ្មបនៅតែមានកង្វះខាតនៅឡើយនៅប្រទេសកម្ពុជា។ តើយើងអាចដោះស្រាយបានដែរឬទេ? ទំព័រទី១០_១១

CSC .Net
FAST INTERNET
SPECIAL DISCOUNT FOR STUDENTS
Only 600 Riels / hour !
Please bring your student's ID when coming for the first time.
Turn the card to see us on the map !
#25, St. 242, Boeng Prolet, 7Makara, Phnom Penh
Tel : (855)92 737 255 or (855)23 224 120
Monday to Friday : 7h30 - 21h Sat. & Sunday : 8h - 21h

កម្មវិធីវិទ្យុ



អេម៉ានូអែល សំឡេងពីព្រះសហគមន៍កាតូលិក !
ភ្នំពេញ : FM 99.5 Mhz ម៉ោង ៧:០០-៧:៣០ រាល់យប់ថ្ងៃសៅរ៍
បាត់ដំបង : FM 91.0 Mhz ម៉ោង ៧:៣០-៨:៣០រាល់យប់ថ្ងៃសៅរ៍
សៀមរាប: FM 102.5 Mhz ១០:០០-១១:០០ រាល់ថ្ងៃសៅរ៍
កំពង់ធំ : FM 88.5 Mhz ម៉ោង ១២:៣០-១:៣០ ថ្ងៃសៅរ៍ថ្ងៃត្រង់
កំពង់ចាម : FM 100.5 Mhz ម៉ោង ៦:៣០-៧:០០ យប់ថ្ងៃអាទិត្យ
ក្រុងព្រះសីហនុ : FM 100.5 Mhz ម៉ោង៦:០០-៧:០០ យប់ថ្ងៃសៅរ៍
កំពត : FM 93.25 Mhz ម៉ោង ៥:០០-៦:០០ រសៀលថ្ងៃសៅរ៍

# រូបថតសម្រាប់លេខនេះ



Photo : S. Philong

ការប្រកួតកីឡាបោកចំបាប់ជាប្រពៃណី ដែលរៀបចំធ្វើឡើងនៅឃុំវិហារសួគ៌ ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាលនាឱកាសបុណ្យភ្ជុំបិណ្ឌកន្លងទៅ ដើម្បីឱ្យប្រជាជននៅក្នុងមូលដ្ឋានរីករាយកំសាន្ត និងជាការទាក់ទាញភ្ញៀវទេសចរណ៍ជាតិ និងអន្តរជាតិ មកពីតំបន់ផ្សេងឱ្យមកចូលរួមកំសាន្តសប្បាយផងដែរ



Photo : S. Philong

ប្រជាជាជនក្នុងភូមិសប្បាយជាខ្លាំងដោយនាំគ្នាពពាក់ពពូនឡើងដើមឈើមើលកីឡាបោកចំបាប់ រៀបចំដោយប្រជាជនក្នុងឃុំវិហារសួគ៌ផ្ទាល់



Photo : S. Philong

កីឡាករប្រណាំងក្របីនាឱកាសបុណ្ណភ្ជុំបិណ្ឌរបស់ប្រជាជនឃុំវិហារសួគ៌ដើម្បីសុំឱ្យបង្កបង្កើនផលបានប្រសើរ **(ឆ្វេង)**

កីឡាករប្រណាំងសេះនាឱកាសបុណ្ណភ្ជុំបិណ្ឌរបស់ប្រជាជនឃុំវិហារសួគ៌ដើម្បីសុំឱ្យប្រជាជនមានសេចក្ដីសុខ **(ស្ដាំ)**



Photo : S. Philong



Photo : S. Philong

កីឡាករអុំទូកនៅវត្តហារ ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល នៅក្នុងពិធីអុំទូកដើម្បីអបអរសាទរពិធីបុណ្យភ្ជុំបិណ្ឌ និងជាការទាក់ទាញភ្ញៀវទេសចរណ៍ឱ្យមកលេងដើម្បីបង្កើនចំណូលដល់ប្រជាជនផងដែរ



Photo : S. Philong

កុមារីជុបអាយុ៧ឆ្នាំ អង្គុយក្នុងផ្ទះលិចទឹករបស់នាងនៅសង្កាត់និរោធ ខណ្ឌមានជ័យ រាជធានីភ្នំពេញ

October-2009:October-2009.qxd 11/06/2010 16:42 Page 3



# "មាតារបស់មនុស្សទាំងអស់ដែលមានជីវិត" (កណ.២:២០)



**លោកប៉ូលរឿង ឆត្រឆ័យ អ្នកសម្របសម្រួលមណ្ឌលផ្សព្វផ្សាយព័ត៌មានព្រះសហគមន៍កាតូលិក (CSC)**

ថ្ងៃខួបកំណើតកូនស្រីរបស់ប្អូនខ្ញុំជិតមកដល់។ កូនសួរអំពី អំណោយពិសេសពីអ្នកម្តាយ។ ប្អូនខ្ញុំឆ្លើយតបថា : "ម៉ាក់ទិញ អំណោយហើយ។ ប៉ុន្តែតើកូនមានរៀបចំអំណោយអ្វីឱ្យម៉ាក់ ឬទេ ?" កូនស្រីនោះឆ្ងល់ណាស់ និងសួរថា : "តើហេតុអ្វីខ្ញុំត្រូវរៀបចំអំណោយឱ្យម៉ាក់"។ ប្អូនខ្ញុំឆ្លើយថា : "កូនដឹងទេ! ម៉ាក់ សម្រាលកូនដោយវះកាត់។ ម៉ាក់បានឈឺពោះណាស់ បាត់បង់ ឈាមច្រើន ហើយអស់កម្លាំងមែនទែន។ ដូច្នេះថ្ងៃខួបកំណើត របស់កូនគឺថ្ងៃដែលម៉ាក់មានការពិបាកណាស់ តើកូននឹកដល់ម៉ាក់នៅថ្ងៃខួបកំណើតរបស់កូនឬទេ?"...។

ប្អូនខ្ញុំបានប្រាប់ខ្ញុំថា គាត់មិនចង់ឱ្យកូនគាត់នឹកដល់តែខ្លួនឯង។ គាត់ចង់អប់រំកូនគាត់ឱ្យនឹកមកដល់ម្តាយ និងអ្នកដទៃដែលធ្វើឱ្យគាត់មានថ្ងៃខួបកំណើតនោះ។

ការសម្រាលកូន គឺជាបទពិសោធន៍ដ៏អស្ចារ្យមួយសម្រាប់ ជីវិតជាម្តាយ។ ជាការពិត ! ម្តាយជាច្រើនយកចិត្តទុកដាក់ថែរក្សាខ្លួនឱ្យល្អបំផុត ពីព្រោះនេះមិនគ្រាន់តែជារឿងសុខភាពរបស់គាត់ ប៉ុន្តែជីវិតរបស់គាត់មានផលប៉ះពាល់ដល់ជីវិតរបស់កូននៅក្នុងផ្ទៃផងដែរ។

ព្រះសហគមន៍កាតូលិកតែងគាំទ្រការលើកកម្ពស់តម្លៃនៃជីវិត ជាពិសេសម្តាយ និងកូន។ ឆ្មបដែលមានបទពិសោធន៍ល្អ និងជំនាញតែងតែជួយដល់អាយុជីវិតរបស់ម្តាយ និងកូនយ៉ាង ពិតប្រាកដ។ ឆ្មប ឬគ្រូពេទ្យជាអ្នកកំណត់អាយុជីវិតរបស់កូន និងម្តាយ។ ប៉ុន្តែក៏មានករណីវិនិច្ឆ័យរបស់គ្រូពេទ្យខុសដែរ។




## កម្មវិធីវិទ្យុព្រះសហគមន៍កាតូលិក

### អ្នកចូលរួមកម្មវិធីអេម៉ាន្ញូអែល "សម្លេងពីព្រះសហគមន៍កាតូលិក" ខែតុលា

-ថ្ងៃអាទិត្យទី២៧ (០៤ តុលា) : លោកបូជាចារ្យអ៊ុន សុន មកពីព្រះសហគមន៍តំបន់កំពត ដែលរួមមានព្រះសហគមន៍កាតូលិកជុំគីរី ត្រពាំងរពៅ និងព្រៃប្រស់។

-ថ្ងៃអាទិត្យទី២៨ (១១ តុលា) : លោកបូជាចារ្យហ្វ្រង់កូ ឡេញីនី មកពីក្រុមគ្រួសារ (PIME) នៅព្រះសហគមន៍កាតូលិកកំពង់ធំ។

-ថ្ងៃអាទិត្យទី២៩ (១៨ តុលា) : លោកបូជាចារ្យស្រ៊ីប្រាម៉ុង វីរជ័យ មកពីក្រុមគ្រួសារសាសនទូតថៃ ប្រចាំនៅព្រះសហគមន៍កាតូលិកកំពង់សោម។

-ថ្ងៃអាទិត្យទី៣០ (២៥ តុលា) : លោកបូជាចារ្យប៉េដ្រូ ហ្គោមេ មកពីក្រុមគ្រួសារយ៉ាល់រ៉ូម៉ាល់របស់ព្រះសហគមន៍បាត់ដំបង។

### "ខ្ញុំត្រូវការអ្នក" ខែតុលា (FM 99.5 Mhz ច័ន្ទ,អង្គារ ម៉ោង១០-១១ព្រឹក)

ថ្ងៃទី០៥ តុលា : ពិសោធន៍ស្នេហ៍។ ថ្ងៃទី០៦ តុលា : ធ្វើយ៉ាងណាដើម្បីគេស្រឡាញ់។ ថ្ងៃទី១២ តុលា : ព្រួយស្នេហ៍។ ថ្ងៃទី១៣ តុលា : ស្រឡាញ់ពិត (ជួយយុវវ័យឱ្យស្គាល់អំពីស្នេហ៍ក្លែងក្លាយ និងស្នេហ៍ពិត)។។ ថ្ងៃទី១៩ តុលា : សន្យាស្នេហ៍។ ថ្ងៃទី២០ តុលា : ធានាស្នេហ៍។ ថ្ងៃទី២៦ តុលា : កម្លាំងស្នេហា។ ថ្ងៃទី២៧ តុលា : ស្នេហ៍នាំអន្តរាយ (មិនយល់អំពីក្តីស្រឡាញ់ មិនស្គាល់ស្នេហ៍ពិត នឹងជួបការលំបាក)។ សូមបញ្ជាក់ថា ប្រធានបទទាំងនេះនឹងមានការចូលរួមបកស្រាយពីវាគ្មិនដែលមានបទពិសោធន៍ និងជំនាញច្បាស់លាស់។ **សូមកុំភ្លេចតាមដាន!**

**ការិយាល័យព័ត៌មានកាតូលិក**
ផ្ទះលេខ ២៥ ផ្លូវលេខ ២៤២ សង្កាត់បឹងព្រលិត ខណ្ឌ ៧ មករា រាជធានី ភ្នំពេញ
Tel/Fax : (855) 23 224 120;
E-mail : csccambodia@gmail.com
Website : www.catholiccambodia.org
អ្នកសម្របសម្រួល : លោកប៉ូលរឿង ឆត្រឆ័យ។ ប្រធាន : លោកលី សុវណ្ណា។
Licence ១៨៣ ពម.ប្រក. / ២៥-មិថុនា-២០០៧

# សេដ្ឋកិច្ច

## ផលិតករខ្មែរគិតអំពីការប្រកួតប្រជែង

**ខាន់ ភីរម្យ**

ទោះបីជាផលិតកម្មក្នុងស្រុកកំពុងរីកចម្រើន។ ប៉ុន្តែម្ចាស់ផលិតកម្មទាំងនោះក៏នៅតែត្អូញត្អែរអំពី បញ្ហាមួយចំនួនទៀតផងដែរ។

លោកប៉ុក លក្សរាសី ប្រធានសិប្បកម្មធម្មជាតិ ខ្មែរ មានប្រសាសន៍ថា បច្ចុប្បន្ននេះ សិប្បកម្មរបស់គាត់មានផលិតផលពីរមុខ ដែលពុំមានផលិតផលនាំចូលពីបរទេសមកប្រកួតប្រជែងនៅឡើយទេ។ ទោះជាយ៉ាងណាទំនិញដែលនាំចូលផ្សេងៗ នៅតែជះឥទ្ធិពលជាអវិជ្ជមានដល់ផលិតផលរបស់លោកដដែល។ លោកបានបញ្ជាក់ថា : ˝មកដល់ពេលនេះ មិនមានប្រទេសណាផលិតស្រាបៀរ និងទឹកខ្មេះពីទឹកត្នោត ហើយនាំចូលមកកាន់ទីផ្សារកម្ពុជា នៅឡើយទេ។ ប៉ុន្តែផលិតផលដែលស្រដៀងៗគ្នានេះ កំពុងវាយលុកលើទីផ្សារខ្លាំងក្លាណាស់˝។ លោកក៏ បានបន្តដែរថា ក្នុងនាមប្រទេសកម្ពុជាជាសមាជិក អង្គការពាណិជ្ជកម្មពិភពលោក យើងពិតជាពុំអាចហាមឃាត់ផលិតផលនាំចូលពីប្រទេសផ្សេងៗបានទេ។



Photo : S. Philong

យើងទទួលស្វាគមន៍ការនាំចូលនេះដែរព្រោះវាក៏អាចធ្វើឱ្យរីកចម្រើនដល់សិប្បកម្មរបស់យើងតាមរយៈ ការប្រកួតប្រជែង។ ប៉ុន្តែអ្វីដែលលំបាកនោះ គឺទំនិញនាំចូលមួយចំនួន និងកំពុងចរាចរណ៍លើទីផ្សារនោះ គ្មានស្តង់ដារ។ លោកក៏បញ្ជាក់ថា : ˝យើងរីករាយនឹងប្រកួតប្រជែងដោយស្មើភាព។ ប៉ុន្តែបើយើងប្រកួតប្រជែងជាមួយផលិតផលដែល គ្មានស្តង់ដារ វាមិនងាយស្រួលទេ នៅខណៈយើង ផលិតពីវត្ថុធាតុដើមអំពីទឹកត្នោត ប៉ុន្តែគេគ្រាន់តែយកអាស៊ីតមកលាយហើយដាក់លក់ តើផលិតផល ណាងាយស្រួលផលិត និងលក់ថោកជាង?˝

លោកហុង ស៊ូត្រា នាយកទីផ្សារនៃសួនកសិករ ខ្មែរ ដែលកំពុងតែផលិតបន្លែអីរ៉ុបនៅខេត្តកំពង់ស្ពឺ មានប្រសាសន៍ថា សព្វថ្ងៃនេះ ផលិតផលរបស់សួន

### សិប្បកម្មធម្មជាតិខ្មែរ

ស្រាបៀរទឹកត្នោត និងទឹកខ្មេះទឹកត្នោតគឺជាផលិតផលពីរប្រភេទ ដែលសិប្បកម្មរបស់លោកប៉ុក លក្សរាសី កំពុងផលិត ហើយដាក់លក់នៅក្នុងទីផ្សារនៅក្នុងប្រទេស។ នេះគឺជាសិប្បកម្មស្របច្បាប់មួយដែលកំពុងដំណើរការផលិតផលិតផលចេញមកពីដើមត្នោត ដែលជានិមិត្តរូបនៃប្រទេសកម្ពុជា។

លោក ប៉ុក លក្សរាសី និយាយថា បច្ចុប្បន្ននេះសិប្បកម្មរបស់លោកកំពុងផ្តល់ការងារដល់ប្រជាជនចំនួន៣០នាក់។ ១៥នាក់ធ្វើការផ្ទាល់នៅរោងសិប្បកម្ម និង១៥នាក់ទៀត គឺជាអ្នកដែលផលិតទឹកត្នោត។ ក្នុងមួយឆ្នាំៗ សិប្បកម្មរបស់លោកប្រើប្រាស់ទឹកត្នោតចំនួន ១០០ ០០០ លីត្រ។ ឆ្នាំក្រោយនឹងត្រូវការបន្ថែមទៀតដោយសារសិប្បកម្មរបស់លោកគ្រោងនឹងផលិតផលិតផលបន្ថែមពីរប្រភេទទៀត"។ បើតាមការបង្ហើបរបស់លោក ផលិតទាំងពីរនោះអាចជាប្រភេទស្រា។

# សុខភាព

## នៅរដូវទឹកជំនន់ យើងបារម្ភអំពីជំងឺដែលបណ្តាលមកពីទឹកកខ្វក់

**ជាត សំភី**

បើតាមប្រសាសន៍របស់លោកវេជ្ជបណ្ឌិតហែម សុខហាន នៅមន្ទីរពេទ្យកុមារជាតិ បានឱ្យដឹងថា: នារដូវទឹកជំនន់ ប្រជាជនអាចជួបប្រទះនូវជំងឺមួយ ចំនួន ដូចជា ជំងឺរាគរូស ជំងឺរាគមួល ជំងឺគ្រុនពោះ វៀន ដង្កូវពោះវៀន និងជំងឺជាច្រើនទៀត។

ទោះបីជាយ៉ាងណា ជំងឺដែលប្រជាជនឧស្សាហ៍ជួបជាងគេ គឺជំងឺរាគរូស និងជំងឺរាគមួល ដែលនេះ អាចផ្តាច់ជីវិតបាន បើគ្មានការព្យាបាលត្រឹមត្រូវ។

សម្រាប់ជំងឺរាគចែកចេញជាបីកម្រិត។ បើរាគស្រាល អ្នកជំងឺអាចផឹកទឹកអូរ៉ាលីត



Photo : S. Philong

ជំនួសជាតិទឹក ដែលបាត់បង់។ ចំណែករាគមធ្យម អ្នកជំងឺផឹកទឹកអូរ៉ាលីតមិនចូលដោយសារគាត់មានក្អួតផង ដូច្នេះ ត្រូវបញ្ជូនមកកាន់មណ្ឌលសុខភាពដាច់ខាត ដើម្បី ព្យាបាល រីឯរាគធ្ងន់ធ្ងរយើងត្រូវតែបញ្ជូនអ្នកជំងឺមកកាន់មន្ទីរពេទ្យ ឬមណ្ឌលសុខភាពជាបន្ទាន់ និង ដាច់ខាត បើយឺតយ៉ាវអ្នកជំងឺពិតជាស្លាប់។ រោគ សញ្ញា ជំងឺរាគធ្ងន់ធ្ងរ គឺអ្នកជំងឺខ្វះជាតិទឹកធ្ងន់ធ្ងរ ធ្វើឱ្យភ្នែកឡើងរូងខ្លាំង យំមិនមានទឹកភ្នែក ស្រេក ទឹក តែផឹកមិនបានស្បែកពោះយារ ទឹកនោមមាន តិចតួច ឬគ្មាន សំពាធឈាមចុះទាប និងជីពចរមិន មាន ដែលជាសញ្ញាគ្រោះថ្នាក់ខ្លាំងណាស់។

ចំណែកឯជំងឺរាគមួលមានរោគសញ្ញាដូចជារាគ ដែរ។ ប៉ុន្តែអ្នកជំងឺឈឺពោះខ្លាំង



Photo : G. Lyda

# អំណាននៅស្រទាប់យុវជនខ្មែរកំពុងរីកចម្រើន

**ខាន់ ភីរម្យ**

ប្រជាប្រិយភាពនៃអំណានកំពុងតែរីកចម្រើន ជាពិសេសនៅក្នុងចំណោមស្រទាប់យុវវ័យនៅក្នុងប្រទេសកម្ពុជា ដែលស្ថិតក្នុងវ័យកំពុងតែសិក្សា។

យុវនារីមួយរូបឈ្មោះថា វីយ៉ា មានវ័យ១៨ឆ្នាំ ដែលសព្វថ្ងៃនេះ នាងកំពុងតែសិក្សានៅវិទ្យាល័យ ត្បូងឃ្មុំ ខេត្តកំពង់ចាម ថ្នាក់ទី១២ បានអះអាងថា នាងមានចំណូលចិត្តស្តាប់វិទ្យុ និងអានទស្សនាវដ្តី។ តែប្រភេទព័ត៌មានដែលនាងតែងតែស្វែងរកនោះ គឺភាគច្រើនជាព័ត៌មានមានលក្ខណៈជាការកំសាន្ត និងទំព័រវិបត្តិស្នេហ៍។ វីយ៉ាបានបញ្ជាក់ដែរថា : "ឱ្យ តែទស្សនាវដ្តីចេញថ្មីៗ ខ្ញុំទិញហើយ តែភាគច្រើន ខ្ញុំចូលចិត្តអាននៅលើទំព័រកំសាន្ត។ ទំព័រខ្លះ ដូចជា ព័ត៌មានសង្គម និងសេដ្ឋកិច្ច ខ្ញុំអានតិចតួចទេ"។

យុវជនតារា អាយុ ២១ឆ្នាំ កំពុងរកទិញសៀវ-ភៅម្តុំវត្តលង្ការ ក៏បានឱ្យដឹងថា រូបគេតែងតែទិញ សៀវភៅថ្មីៗ មកអានជានិច្ច ពិសេសគឺរឿងកំប្លែង ដើម្បីចែករំលែកការសប្បាយជាមួយមិត្តភក្តិ និង កាត់បន្ថយការអផ្សុក ពេលទំនេរពីរៀនសូត្រ។

តារា បានបញ្ជាក់ថា: "នៅសាកលវិទ្យាល័យ ខ្ញុំទៅបណ្ណាល័យដើម្បីអានឯកសារនេះ ឯកសារនោះ ឬជួនកាលឆែកអ៊ីនធឺណិត។ ប៉ុន្តែនៅផ្ទះខ្ញុំចូលចិត្ត អានព័ត៌មានប្លែកៗ និងរឿងកំសាន្តខ្លី"។

ចំពោះបញ្ហាអំណាននេះលោកយន្ត ឬទ្ធី ប្រធាន សហព័ន្ធសហជីពយុវជនខ្មែរ បានមានប្រសាសន៍ថា អំណានមានសារៈសំខាន់ណាស់ ហើយវាជាការល្អ ហើយដែលយុវជនខ្មែរនៅក្នុងសម័យនេះចាប់ផ្តើមនិយមការអានឡើងវិញ។ លោកបានបញ្ជាក់ថា : "អំណានជាឃ្លាំងនៃចំណេះដឹងទូទៅមួយដ៏សំខាន់របស់មនុស្ស ទោះគាត់អានរឿងកំប្លែង ឬព័ត៌មាន កំសាន្តទោះអ្វីក៏ដោយ ឱ្យតែគាត់អាន"។ បើតាម លោកយន្ត ឬទ្ធី ប្រជាប្រិយភាពនៃការអាននេះមិនមែនរីកចម្រើនតែនៅក្នុងស្រទាប់យុវជន និងយុវ-នារីទេ តែនៅក្នុងស្រទាប់មហាជនទូទៅ។ លោក បានបន្តដែរថា មកដល់នឹងពេលនេះ យើងសង្កេតឃើញការអាន មានស្ទើរនៅគ្រប់ទីកន្លែង។លោក បានបញ្ជាក់ទៀតថា: "សម័យមុន យើងឃើញគេអាចអានតាមតែបណ្ណាល័យ បណ្ណាគារ ឬក៏កន្លែងលក់សៀវភៅទេ តែពេលនេះសូម្បីតែតុកាហ្វេ ក៏មានអ្នកអាន អ្នកលក់សៀវភៅ ឬកាសែតសម្រាប់ អានដែរ។ នេះគឺជាការរីកចម្រើននៅកម្ពុជា"។

ស្របពេលនឹងអ្វីដែលលោកយន្ត ឬទ្ធី បានលើក ឡើង អំពីផលប្រយោជន៍នៃការអាននេះ យុវនារី វីយ៉ា ក៏បានការពារចំណង់ចំណូលចិត្តនាងថា មូល-ហេតុដែលគាត់ចង់អានទំព័រ ឬព័ត៌មានដែលទាក់-ទងនឹងការកំសាន្ត និងវិបត្តិស្នេហ៍នេះ យ៉ាងហោចណាស់ក៏អាចឱ្យនាងស្វែងរកមធ្យោបាយសម្រាប់ទប់ទល់ និងដោះស្រាយពេលណាដែលនាងបានជួបវិបត្តិទាំងអស់នោះផងដែរ។ វីយ៉ាបានបញ្ជាក់ថា:

October-2009:October-2009.qxd 11/06/2010 16:42 Page 6

## កសិកម្ម

# ជំងឺរបស់ស្រូវ និងវិធានការការពារ

**ជាត សំភី**


Photo : P. Samphy

ដើម្បីធ្វើស្រែឱ្យបានទិន្នផលខ្ពស់ កសិករត្រូវតែប្រឹងប្រែងកំចាត់ឧបសគ្គទាំងឡាយ ដែលរាំងស្ទះដល់ការលូតលាស់ របស់ដំណាំស្រូវ ដែលដូចជាជំងឺក្រាដែលវាបង្កឡើងដោយពពួកវីរុស និងជំងឺដែល បណ្តាលមកពីដំណាំស្រូវខ្វះជីជាតិ។

លោកឱ ធី មន្ត្រីកម្មវិធីនៃអង្គការសេដាកមានប្រសាសន៍ថា:

ជំងឺក្រា ឬជំងឺបួល ដែលជាភាសាសាមញ្ញរបស់ កសិករ គឺបណ្តាលមកពីវីរុស។ រោគសញ្ញារបស់វាគឺមុនដំបូង នៅក្នុងស្រែរបស់យើងមានស្រូវ ១គុម្ព ឬក៏ពីរគុម្ព ចេញពណ៌ក្រហម។ បើយើងទៅពិនិត្យគឺយើងមិនឃើញមានសត្វល្អិត ឬអ្វីទេ។ ប៉ុន្តែកាល ណាយើងទុកយូរទៅ ស្រូវនៅពេញមួយស្រែឡើង ក្រហម និងងាប់ទាំងអស់។ ដូច្នេះវិធានការរបស់ យើងគឺដកនូវគុម្ពណាដែលមានជំងឺដាក់ក្នុងរណ្តៅ ដុត និងកប់ចោល។ បើយើងបោះចោលផ្តេសផ្តាស វាអាចឆ្លងទៅស្រែផ្សេងទៀត។

ជំងឺក្រានេះអាចឆ្លងតាមរយៈពូជដែលមានជំងឺ និងការប្រើសម្ភារៈកសិកម្ម ដូចជា រនាស់ ឬនង្គ័ល លើស្រែដែលមានជំងឺ រួចយកមកប្រើប្រាស់នៅលើ ស្រែដែលល្អ។ ដូច្នេះដើម្បីការពារនូវជំងឺក្រា យើងត្រូវជ្រើសរើសយកតែពូជល្អមកប្រើ ហើយមុននឹង សាប យើងត្រូវយកទៅត្រាំក្នុងទឹកស្តៅសិន ដើម្បីការពារមេរោគ។ ម្យ៉ាងទៀតយើងត្រូវតែសំអាតឧបករណ៍កសិកម្មផ្សេងៗ ដូចជារនាស់ ឬនង្គ័លឱ្យ បានស្អាត។ ចំណែកកញ្ច្រែ ឬល្អី ដែលយើងដាក់ពូជ យកទៅសាប យើងត្រូវប្រយ័ត្ន កុំឱ្យមានពូជដែលមានជំងឺនៅលាយឡំ។

ជំងឺមួយទៀត គឺវាបណ្តាលមកពីកង្វះសារធាតុ ចិញ្ចឹម ដូចជាកង្វះជាតិអាសូត ប៉ូតាស្យូម ឬក៏ជាតិ ផូស្វ័រ ដែលវាបណ្តាលឱ្យស្រូវលូតលាស់ មិនល្អ និងចេញ ពណ៌សម្បុរខុសៗគ្នា។ វិធានការការពារជំងឺ

## បរិស្ថាន

# ទេសចរណ៍ធម្មជាតិ និងអភិរក្សបរិស្ថាន

បើតាមប្រសាសន៍របស់លោកវ៉ា មឿន នាយកប្រតិបត្តិនៃអង្គការម្លប់បៃតងបានឱ្យដឹងថា:


Photo : P. Samphy

ទេសចរណ៍ធម្មជាតិគឺការងារទេសចរណ៍ដែលយើងយកធនធានធម្មជាតិមកធ្វើជាគ្រឿងដើម្បីទាក់ទាញភ្ញៀវទេសចរណ៍។ ហើយធនធានធម្មជាតិ ដែលយើងយកមកទាក់ទាញទេសចរណ៍បានមានដូចជាទឹកជ្រោះ ព្រៃឈើ ឬកន្លែង ដែលមានសត្វព្រៃ និងសត្វកម្រជាដើម។

ភ្ញៀវដែលមកកំសាន្ត ភាគច្រើនជាមនុស្សវ័យ ជំទង់ ព្រោះទេសចរណ៍ធម្មជាតិ មានលក្ខណៈផ្សងព្រេងបន្តិច។ ដូច្នេះស្ថាប័នពាក់ព័ន្ធ និងប្រជាជនត្រូវតែចូលរួមទាំងអស់គ្នាដើម្បីធានាឱ្យភ្ញៀវចូលទៅ ដល់តំបន់ធម្មជាតិ ដែលគេចង់ទៅ។ មិនត្រឹមតែ ប៉ុណ្ណោះកន្លែងស្នាក់នៅសមរម្យ ម្ហូបអាហារ និង ការធានាសុវត្ថិភាពសន្តិសុខ ក៏ត្រូវតែធានាឱ្យបាន ផងដែរដើម្បីទាក់ទាញភ្ញៀវ។

ទេសចរណ៍ធម្មជាតិ គឺមានសារៈសំខាន់ណាស់ ពីព្រោះវាជាផ្នែកមួយដើម្បីធានាដល់ការអភិរក្សបរិស្ថាន។ នេះគឺមានន័យថា ដើម្បីឱ្យទេសចរណ៍ ហ្នឹងអាចដំណើរការទៅបាន

## អង្គការ

# អ្នកក្រីក្របានទទួលការសង្គ្រោះពីសមាគមពន្លកថ្មី

**ជាត សំភី**

ជារៀងរាល់ខែ មានពីរដង ដែលសមាគមពន្លក ថ្មីចុះទៅជួយពិនិត្យព្យាបាល និងផ្តល់ថ្នាំសង្កូវ ដល់ប្រជាជននៅស្រុកពីរនៅខេត្តកណ្តាល គឺស្រុកល្វា- ឯម និងស្រុកកណ្តាលស្ទឹង។ នៅក្នុងស្រុក ល្វាឯម សមាគមជួយនៅឃុំ២ គឺឃុំសារិកាកែវ និងអរិយ- ក្សត្រ។ ចំណែកស្រុកកណ្តាលស្ទឹង សមាគមជួយបី ឃុំ គឺឃុំគងនយ ឃុំព្រះពុទ្ធ និងឃុំទៀង។ កម្មវិធីនេះបង្កើតឡើងតាំងពីឆ្នាំ ២០០៥។

លោកស៊ិន ទូច ប្រធានគម្រោងរបស់សមាគមពន្លកថ្មី មានប្រសាសន៍ថា កម្មវិធីនេះត្រូវធ្វើឡើង មានជាប់ពាក់ព័ន្ធកម្មវិធីអប់រំនៃសមាគមពន្លកថ្មី។ ដោយសារឪពុកម្តាយឃើក្មេងៗក៏ចេះតែនៅមើល ថែពួកគាត់ ធ្វើឱ្យគេបាត់បង់ការរៀនសូត្រ។ ដូច្នេះ សមាគមបង្កើតកម្មវិធីនេះឡើងក្នុងគោលបំណង ជួយព្យាបាលឪពុកម្តាយដើម្បីការពារកូនរបស់ពួក គាត់កុំឱ្យឈប់រៀន។ ហើយម្យ៉ាងទៀតដោយសារ មានជំនួយពីសប្បុរសជននានា សមាគមពន្លកថ្មីក៏បានបន្តកម្មវិធីនេះ និងសម្រាប់អ្នកទូទៅដែរ។



Photos : Les nouvelles pousses

វេជ្ជបណ្ឌិតស្ម័គ្រចិត្តបារាំងពីរនាក់ និងនិស្សិតសាលាពេទ្យចុះកម្មសិក្សា ជួយពិនិត្យព្យាបាលជំងឺឱ្យប្រជាជនមិនគិតថ្លៃ

កញ្ញាធីម ស៊ីនឿត អ្នកទទួលខុសត្រូវផ្នែកអប់រំ និងសុខភាពនៃសមាគមពន្លកថ្មី និយាយថា សព្វថ្ងៃ សមាគមមានវេជ្ជបណ្ឌិតស្ម័គ្រចិត្តបារាំងមួយរូប។ ក្នុងការទៅម្តងៗ យើងអាចពិនិត្យ និងព្យាបាលឱ្យ ប្រជាជនបាន ពី២៥ ទៅ៣០នាក់ និងមានបី ឬបួន នាក់ដែរ ដែលយើងត្រូវបញ្ជូនគាត់ទៅមន្ទីរពេទ្យ ធំ។

កញ្ញាធីម ស៊ីនឿត បន្តទៀតថា បើជំងឺធម្មតា យើងអាចពិនិត្យ ព្យាបាល និងឱ្យថ្នាំ ដោយមិនគិត តម្លៃអ្វីទាំងអស់ នៅហ្នឹងទីកន្លែង មានដូចជា ឈឺ ក្បាល ឈឺឆ្អឹងឆ្អែង និងគ្រុនក្តៅ-ល-។ ចំណែកឯ ជំងឺធ្ងន់ ដូចជារោគស្ត្រី ទឹកនោមផ្អែម របេង ឬជំងឺ បេះដូង យើងបញ្ជូនគេទៅមន្ទីរពេទ្យរុស្ស៊ី កុសមៈ ពេទ្យរបេង ឬពេទ្យកាល់ម៉ែត

# ប្រជាជនរីករាយនឹងកម្មវិធីសុខភាពរបស់សមាគមពន្លកថ្មី

បើតាមប្រសាសន៍របស់លោកស៊ិន ទូច បានឱ្យដឹងថា កម្មវិធីសុខភាពរបស់សមាគមពន្លកថ្មីគឺបាន ជួយទៅដល់គ្រួសារច្រើនមែនទែន និងរាប់ពុំអស់ ចាប់តាំងពីមានការបង្កើតមក។

តាមរយៈនេះដែរលោកប៊ុន សម្បត្តិ អាយុ ៧០ ឆ្នាំ រស់នៅភូមិតាស្គរ ឃុំសារិកាកែវ ស្រុកល្វាឯម ខេត្តកណ្តាល មានប្រសាសន៍ថា : "ខ្ញុំបានទទួលការ ពិនិត្យពីវេជ្ជបណ្ឌិតបារាំងនៃសមាគមពន្លកថ្មីតាំង ពីខែកក្កដា ឆ្នាំ២០០៩។ ខ្ញុំមានជំងឺលើសឈាម ទឹក នោមផ្អែម និងក្រពះ។ លោកវេជ្ជបណ្ឌិតបារាំងបាន ស្នើឱ្យខ្ញុំទៅព្យាបាលនៅមន្ទីរពេទ្យលោកសង្ឃនៅ ក្រុងភ្នំពេញដោយខាងសមាគមពន្លកថ្មីជាអ្នកចេញ ថវិកាពិនិត្យ ព្យាបាល និងថ្លៃថ្នាំទាំងអស់។ ឥឡូវ ខ្ញុំបានធូរ ៣៥% ហើយ។ ខ្ញុំមានអារម្មណ៍ត្រេកអរ ខ្លាំងមែនទែន។



សមាគមននេះហាក់ប្រស់ជីវិតខ្ញុំ។ ពេលនេះ ខ្ញុំយល់ច្បាស់ថា មិនដែលមាននរណាគេ មានសន្តានចិត្តល្អដូច្នេះ ហើយបើនិយាយអំពីអំពើ មនុស្សធម៌វិញ ខ្ញុំមិនដែលធ្លាប់ជួបអ៊ីចឹងផង"។

ចំណែកអ្នកស្រីណាំ វណ្ណា អាយុ៤៧ឆ្នាំ កសិករ នៅភូមិតាស្គរ ឃុំសារិកាកែវ ស្រុកល្វាឯមដែរ មានប្រសាសន៍រៀបរាប់ក្នុងសម្លេងខ្សោយថា: "ខ្ញុំមាន ជំងឺទឹកនោមផ្អែម។ ខ្ញុំបានសមាគមពន្លកថ្មី គេជួយ តាំងពីខែប្រាំឆ្នាំ ២០០៨ មកម្ល៉េះ។ ពីដំបូងសមា- គមនេះបានមកមើលខ្ញុំដល់ផ្ទះ។ គេថា ខ្ញុំពិតជាអ្នក ក្រីក្រមែន។

October-2009:October-2009.qxd 11/06/2010 16:42 Page 8





Photo : S. Philong

## ទុនវិនិយោគចិនទៅកម្ពុជា កើនដល់ ៦៧០០ លានដុល្លារ

ស្ពានព្រែកក្តាមឆ្លងទន្លេសាប នៅស្រុកពញាឮ ខេត្តកណ្តាល កំពុងតែសាងសង់ឡើងដោយក្រុមហ៊ុនចិនមួយលើទឹកប្រាក់ប្រមាណ ៣១លានដុល្លារ ។ ស្ពាននេះមានប្រវែង ៩៨១ ម៉ែត្រ ហើយគ្រោងនឹងសង់រួចរាល់ក្នុងខែមេសា ឆ្នាំ ២០១០ ។

នៅក្នុងពិធីតភ្ជាប់ស្ពានព្រែកក្តាមនេះនៅពាក់កណ្តាលខែកញ្ញា សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រីកម្ពុជា មាន ប្រសាសន៍ថា ចិនគឺជាដៃគូអភិវឌ្ឍន៍ដ៏សំខាន់របស់កម្ពុជា ហើយមកដល់ពេលនេះទុនវិនិយោគរបស់ចិនឡើងដល់ ៦៧០០លានដុល្លារ ។ ប្រទេសចិន បានដាក់ទុនរកស៊ីវិស័យទេសចរណ៍ ដែលមានប្រមាណ ៤០០០លានដុល្លារ ក្រៅពីនេះ មានវិស័យហេដ្ឋារចនាសម្ព័ន្ធ ប្រមាណ ១៤០០ដុល្លារ សំណង់ ១០០០ លានដុល្លារ និង វិស័យកសិកម្ម មានប្រមាណជា ៣០០លានដុល្លារផងដែរ ។

## ធនាគារ ADB និងកម្ពុជា ចុះហត្ថលេខាលើកិច្ចព្រមព្រៀងហិរញ្ញវត្ថុ៣៧,៣លានដុល្លារ

កិច្ចព្រមព្រៀងផ្នែកហិរញ្ញវត្ថុតម្លៃ ៣៧,៣លានដុល្លារ បានត្រូវចុះហត្ថលេខាដោយឯកឧត្តមគាត ឈន់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាមួយលោកឡូរ៉ង់ ហ្រ្គែនវូត អនុប្រធាន ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ។

យោងទៅតាមកិច្ចព្រមព្រៀងនេះ

## ជប៉ុនជ្រើសរើសបាននាយករដ្ឋមន្ត្រីថ្មីចេញពីការបោះឆ្នោត



លោកយូគីអូ ហាតូយ៉ាម៉ា និងគណៈរដ្ឋមន្ត្រី ថ្មីរបស់ជប៉ុន បានចាប់ផ្តើមការងារ កាលពីថ្ងៃ ទី១៧ ខែកញ្ញា កន្លងទៅ ក្រោយពីគណបក្សប្រជាធិបតេយ្យរបស់លោកយូគីអូ ហាតូយ៉ា- ម៉ា បានដណ្តើមជ័យជម្នះលើគណបក្សរំដោះប្រជាធិបតេយ្យដែលជាគណបក្សកាន់អំណាច ចាស់លើការបោះឆ្នោតកាលពីពេលថ្មីៗនេះ ។

លោកយូគីអូ ហាតូយ៉ាម៉ា កើតនៅទីក្រុងតូក្យូក្នុងប្រទេសជប៉ុន ។ លោកបានបញ្ចប់ការសិក្សាផ្នែកវិស្វករនៅឆ្នាំ១៩៦៩ ហើយបានទទួលសញ្ញាបត្របណ្ឌិតលើផ្នែកវិស្វកម្មនៅក្នុងឆ្នាំ១៩៧៦ ។ រយៈពេល ១០ ឆ្នាំក្រោយមក លោកបានចាប់ផ្តើមប្រឡូកនៅក្នុងឆាកនយោបាយនៅ ក្នុងគណបក្សរំដោះប្រជាធិបតេយ្យ ។ ប៉ុន្តែលោកបានចាកចេញពីគណ- បក្សនេះទៅបង្កើតគណបក្សថ្មីមួយ រួចឈានទៅដល់បង្កើតគណបក្ស ប្រជាធិបតេយ្យក្នុងឆ្នាំ១៩៩៣ ។ លោកក៏បានតស៊ូនយោបាយតទល់ជា

## សក់អាចបង្កើតថាមពលអគ្គីសនី

បន្ទះពន្លឺព្រះអាទិត្យថ្មីមួយ ដែលផលិតឡើងដោយសក់របស់ មនុស្សបានត្រូវរកឃើញដោយអ្នកវិទ្យាសាស្ត្រវ័យក្មេង ឈ្មោះ មីឡាន កាកិ ជនជាតិនេប៉ាល់ ដែលអាយុទើបតែ ១៨ឆ្នាំ ។

តាមរបកគំហើញរបស់មីឡាន កាកិ សក់របស់មនុស្ស អាចយកមកប្រើប្រាស់ជំនួសសារធាតុស៊ីលីកូន ដោយសារតែវាគឺជាសរីរាង្គដែលអាចចម្លងកម្តៅ អាចបំប្លែង និងផ្លាស់ប្តូរថាមពលបាន ដែលគេអាចយកទៅបង្កើតជាអគ្គីសនី ។

ជាមួយនឹងការរកឃើញថ្មីនេះ យុវជនរូបនេះបានផលិតបន្ទះថាមពលមួយដែលអាចស្រូបកម្តៅ ហើយក៏បំប្លែងចេញជាអគ្គី- សនីសម្រាប់ប្រើប្រាស់បាន។ មិនត្រឹមតែប៉ុណ្ណោះ វាក៏មានតម្លៃ ថោកទៀតផង។ បើតាមការអះអាងរបស់យុវជនរូបនេះបានឱ្យ ដឹងថា គេអាចច្នៃបន្ទះស្រូបពន្លឺព្រះអាទិត្យធ្វើពីសក់ ដែលអាចផលិតថាមពលកម្លាំង ៩វ៉ុល និងចំណាយអស់ថវិកាត្រឹមតែ ៣៨ ដុល្លារតែប៉ុណ្ណោះ។

October-2009:October-2009.qxd 11/06/2010 16:42 Page 9



# សារមន្ទីរជាតិអភិរក្ស និងតាំងបង្ហាញវត្ថុមរតកវប្បធម៌ខ្មែរ

## ខាន់ ភីរម្យ

*វត្ថុបុរាណ គឺជាតឹកតាងមួយដ៏សំខាន់របស់វប្បធម៌ខ្មែរ។ សព្វថ្ងៃនេះកិច្ចការអភិរក្សវត្ថុទាំងនេះកំពុងធ្វើដោយសារមន្ទីរជាតិនៅរាជធានីភ្នំពេញ។ លោកហាប់ ទូច ប្រធានសារមន្ទីរជាតិបានផ្តល់បទសម្ភាសន៍ជាមួយនឹងអ្នកនាំសារក្នុងខ្លឹមសារដូចខាងក្រោម:*

**អ្នកនាំសារ : តើពេលសព្វថ្ងៃសារមន្ទីរជាតិមានតួនាទីអ្វីក្នុងការអភិរក្សមរតកវប្បធម៌ខ្មែរ ?**

**លោកហាប់ ទូច :** សារមន្ទីរជាតិជាមជ្ឈមណ្ឌលវប្បធម៌ដ៏ធំមួយនៅក្នុងព្រះរាជាណាចក្រកម្ពុជាសម្រាប់ការអភិរក្ស និងការពារបេតិកភណ្ឌវប្បធម៌ និងប្រវត្តិសាស្ត្ររបស់ខ្មែរ។ យើងក៏ដឹងថាវត្ថុបុរាណ និងប្រាសាទបុរាណនៅក្នុងប្រទេសកម្ពុជា មានច្រើនណាស់។ ប៉ុន្តែដោយឆ្លងកាត់សង្គ្រាមជា ច្រើនវត្ថុបុរាណបានខូចខាត និងបាត់បង់១ចំនួន។ ដូច្នេះដើម្បីការពារវត្ថុទាំងអស់នេះ សារមន្ទីរជាតិបានខិតខំធ្វើនូវកិច្ចការប្រមែប្រមូលវត្ថុបុរាណខ្មែរ ដែលនៅក្រៅប្រទេស



Photo : S. Philong

សារមន្ទីរជាតិមើលពីមុខ ស្ថិតនៅខាងជើងព្រះបរមរាជវាំង រាជធានីភ្នំពេញ

និងនៅតាមប្រាសាទបុរាណនានាដើម្បីយកមករក្សាទុកនៅទីនេះ។ សារមន្ទីរជាតិគឺជាឃ្លាំងយ៉ាងធំមួយសម្រាប់ការពារសម្បត្តិ វប្បធម៌ទាំងអស់នេះឯង។

**អ្នកនាំសារ : តើសារមន្ទីរជាតិបានធ្វើកិច្ចការអ្វីខ្លះក្នុងការប្រមែប្រមូលសម្បត្តិវប្បធម៌ទាំងនោះ ?**

**លោកហាប់ ទូច :** សារមន្ទីរមានកិច្ចសហការជាមួយនិងប្រជាពលរដ្ឋ និងអាជ្ញាធរ មានសមត្ថកិច្ចដែលលោកបានរកឃើញវត្ថុបុរាណ ឬមួយក៏រឹប អូសពីជនខិលខូចដើម្បីយកវត្ថុទាំងនេះ មករក្សាទុក។ លើសពីនេះយើងក៏មានសហការ ជាមួយនិងភ្នាក់ងារអន្តរជាតិនានា ដូចជាអង្គការយូណេស្កូជាដើម។ ពិសេសថ្មីៗនេះយើងក៏បានទទួលវត្ថុបុរាណដែលរដ្ឋាភិបាលទាមទារពីប្រទេសថៃផងដែរ។

**អ្នកនាំសារ : តើសារមន្ទីរជាតិមានដំណើរការអភិរក្សវត្ថុបុរាណយ៉ាងដូចម្តេចដែរ ?**

**លោកហាប់ ទូច :** កិច្ចការដែលយើងកំពុងតែធ្វើនៅពេលនេះ គឺទីមួយ ការពារ។ ទីពីរ គឺអភិរក្ស និងជួសជុល។ នៅសារមន្ទីរជាតិសព្វថ្ងៃនេះ យើងមានរោងជាងបីសម្រាប់ធានាកិច្ចការអភិរក្សបេតិកភណ្ឌទាំងនោះ។ រោងជាងទីមួយ រោងជាងអភិរក្ស និងជួសជុលវត្ថុពីថ្ម ទីពីរគឺរោងជាងអភិរក្ស និងជួសជុលវត្ថុពីលោហៈធាតុ និងទី៣ គឺរោងជាង អភិរក្ស និងជួសជុលកុលាលភាជន៍។

**អ្នកនាំសារ : តើសារមន្ទីរជាតិបានកំពុងតែអភិរក្ស និងការពារវត្ថុបុរាណប៉ុន្មាន ?**

**លោកហាប់ ទូច :** វត្ថុបុរាណនៅទីនេះ មានច្រើនណាស់។ ប៉ុន្តែយើងបានចែកវត្ថុដែលរក្សាទុក ជា៤សំខាន់ៗ គឺទី១ វត្ថុអំពីថ្ម ទី២ វត្ថុធ្វើពីលោហៈ ធាតុ ទីបីគឺវត្ថុកុលាលភាជន៍ ឬសេរ៉ាមិច និងទីបួន គឺវត្ថុអំពីឈើ។ យើងក៏កំពុងរៀបចំផ្នែកមួយទៀត



Photo : S. Philong

សម្បត្តិបេតិកភណ្ឌវប្បធម៌រាប់ពាន់ប្រភេទត្រូវបានប្រមូលមកទុកប្រកបដោយសុវត្ថិភាពដើម្បីសិក្សា ជួសជុល អភិរក្ស និងដាក់តាំងបង្ហាញជូនដល់សាធារណជនទូទៅចូលទស្សនានៅសារមន្ទីរជាតិ

## ឧបសគ្គចម្បងក្នុងការរក្សាបេតិកភ័ណ្ឌ

ជាធម្មតា ការអភិរក្សាមានទំហំធំធេង ហើយធ្វើមិនចេះចប់ទេ។ ប៉ុន្តែនាពេលបច្ចុប្បន្ននេះសារមន្ទីរជាតិនៅខ្វះធនធានមនុស្ស និងសម្ភារៈបរិក្ខាជាច្រើន។ សារមន្ទីរជាតិសព្វថ្ងៃនេះ មានធនធានមនុស្ស និងសម្ភារៈល្មមនឹងអភិរក្ស និងការពារវត្ថុនៅក្នុងវង្វង់សារៈមន្ទីរតែប៉ុណ្ណោះ។ លោកហាប់ ទូច មានប្រសាសន៍ថា អ្នកអភិរក្សដូចជាវេជ្ជបណ្ឌិតដូច្នេះដែរ។ ប៉ុន្តែវេជ្ជបណ្ឌិតអាចសួរអ្នកជំងឺបាន។ អ្នកអភិរក្សមិនអាចសួរបានទេ ពីព្រោះវត្ថុមិនអាចនិយាយបាន។ ដូច្នេះដើម្បីជួសជុលអ្វីមួយវាទាមទារការសិក្សាច្រើនណាស់។ យើងមិនអាចទៅសួរថ្មបានទេ។

October-2009:October-2009.qxd 11/06/2010 16:42 Page 10



# កង្វះខាតឆ្មបនៅតែមាន ប៉ុន្តែអាចនឹងលុបបំបាត់

**ខាន់ ភីរម្យ**

កម្ពុជាដែលគេចាត់ទុកថា គឺជាប្រទេសមួយនៅក្នុងចំណោមប្រទេសដែលមានអត្រាមរណមាតា និងទារកខ្ពស់ជាងគេមួយ នៅក្នុងតំបន់នៅតែជួប បញ្ហាកង្វះខាតឆ្មបជំនាញ ជាពិសេសគឺនៅតំបន់ជនបទ។ ប៉ុន្តែទោះជាយ៉ាងណា បញ្ហានេះត្រូវបានគេរំពឹងថា នឹងត្រូវដោះស្រាយនៅក្នុងពេលឆាប់ៗ។

លោកស្រីប៉ែន សុផាណារ៉ា ជាមន្ត្រីព័ត៌មាននៃអង្គការយូអេនអេហ្វភីអេ (UNFPA) ដែលជាផ្នែក មួយនៃអង្គការសហប្រជាជាតិ បានមានប្រសាសន៍ ថា នៅក្នុងពេលបច្ចុប្បន្ននេះ បញ្ហាសុខភាពមាតា និងទារក ជាបញ្ហាមួយដែលរដ្ឋាភិបាល ជាពិសេស ក្រសួងសុខាភិបាល និងដៃគូនានា កំពុងតែយកចិត្ត ទុកដាក់។ តែទោះបីជាយ៉ាងណាកម្ពុជានៅតែជួប បញ្ហាកង្វះខាតឆ្មប និងឧបករណ៍ ជាពិសេស គឺនៅតំបន់ជនបទដាច់ស្រយាល។

លោកស្រីបានបញ្ជាក់ថា: "សព្វថ្ងៃ នៅទូទាំងប្រទេសកម្ពុជា មានមណ្ឌលសុខភាពទាំងអស់ចំនួនប្រមាណជា៩០០កន្លែង និងមានឆ្មបកំពុងតែបម្រើ ការប្រមាណ ៣៣០០នាក់។ ប៉ុន្តែនៅក្នុងប្រទេស នៅមានមណ្ឌលសុខភាព ចំនួនប្រមាណ ៧០កន្លែង ទៀត ដែលមិនទាន់មានឆ្មប"។

បើយោងតាមការអះអាងរបស់លោកស្រីសុផាណារ៉ា បញ្ហាកង្វះខាតឆ្មបនេះក៏នឹងលែងចោទមានជាបញ្ហាហើយនៅឆ្នាំខាងមុខ។ ប៉ុន្តែលោកស្រីមិន ហ៊ានព្យាករថា នៅពេលណាច្បាស់លាស់ដែរដោយគ្រាន់តែអះអាងថា គឺប្រហែលជានៅក្រោយពេលដែលនិស្សិតផ្នែកឆ្មប ដែលកំពុងតែបណ្តុះបណ្តាលបានបញ្ចប់ការសិក្សារបស់ពួកគេ។ ប៉ុន្តែទោះបីជាយ៉ាងនេះ បញ្ហាកង្វះខាតឆ្មបនេះនៅតែជាក្តីកង្វល់មួយដែលជាពិសេសគឺនៅតំបន់ដាច់ស្រយាល។

លោកស្រីបានបញ្ជាក់ថា: "ឆ្មបដែលទទួលការបណ្តុះបណ្តាលហើយ ភាគច្រើនគឺមិនចង់ទៅបម្រើការនៅតំបន់ដែលខ្វះខាតទេ ដោយសារបញ្ហាកង្វះ ទំនាក់ទំនង និងហេដ្ឋារចនាសម្ព័ន្ធជាដើម។ តែទោះ បីជាយ៉ាងណាក៏ដោយ យើងរំពឹងថា នឹងលែងមាន បញ្ហានៅថ្ងៃអនាគតដោយសារតែរដ្ឋាភិបាលបានជ្រើសរើសយកនូវធនធានមនុស្សដែលចេញមកពីតំបន់ដែលជួបកង្វះខាតនោះផ្ទាល់"។

ជុំវិញបញ្ហានេះលោកស្រីអ៊ូ សារឿន ជាប្រធាន សមាគមឆ្មបកម្ពុជា បានមានប្រសាសន៍ថា កម្ពុជាអាចនឹងមានឆ្មបគ្រប់គ្រាន់នៅក្នុងឆ្នាំ២០១១ ខាង មុខ។ លោកស្រីបានបន្តទៀតដែរថា



Photo : S. Philong

## អត្រាស្លាប់របស់មាតា និងទារកនៅក្នុងពេលសម្រាលបុត្រធ្លាក់ចុះ

លោកស្រីប៉ែន សុផាណារ៉ា មន្ត្រីព័ត៌មាននៃអង្គការយូអេនអេហ្វភីអេ (UNFPA) អះអាងថា អត្រាមរណភាពទារក និងមាតានៅកម្ពុជាពេលសម្រាលនៅកម្ពុជាកំពុងមាននិន្នាការធ្លាក់ចុះ។ លោកស្រីមានប្រសាសន៍ថា លោកស្រីមិនមានតួលេខទេ តែលោកស្រីបានរំពឹងថា អត្រាមរណភាពរបស់កុមារមានការថយចុះច្រើន។ ចំណែកអត្រាមរណភាពមាតានៅក្នុងពេលសម្រាលវិញ ក៏មានការធ្លាក់ចុះដែរ។

យោងតាមការសិក្សាចុងក្រោយមួយរបស់អង្គការសុខភាពពិភពលោកនៅក្នុងឆ្នាំ២០០៥ បានឱ្យដឹងថា អត្រាស្លាប់របស់កុមារនៅកម្ពុជា មានចំនួន៩៥នាក់ នៅក្នុងកំណើត ១០០០នាក់។ ចំណែកអត្រាស្លាប់របស់មាតានៅពេលសម្រាលវិញ គឺមានចំនួន ៤៧២នាក់ នៅក្នុងចំណោមស្ត្រីសម្រាលកូនចំនួន ១០០០០០នាក់។ អត្រានេះគឺមានខ្ពស់ជាងគេនៅក្នុងចំណោមប្រទេសនៅក្នុងតំបន់អាស៊ីអាគ្នេយ៍។

# ...នៅពេលខាងមុខ



កង្វះខាតឆ្មបមានសឹងតែគ្រប់ខេត្តទាំងអស់ជាពិសេសនៅតំបន់ដាច់ស្រយាល។ តែខេត្តដែលខ្វះច្រើនជាងគេសព្វថ្ងៃនេះមាននៅឆ្ងាយៗ ដូចជាខេត្តស្ទឹងត្រែង រតន- គិរី និងខេត្តកោះកុងជាដើម។

ក្រៅពីកង្វះខាតឆ្មបហើយនោះ នៅមានបញ្ហាមួយទៀតដែលបណ្តាលឱ្យអត្រាមរណភាពរបស់មាតា និងទារកអំឡុងពេលមានគភ៌ ពេលសម្រាល និងក្រោយសម្រាល នៅតែខ្ពស់នោះ គឺដោយសារស្ត្រីជាច្រើននៅតំបន់ជនបទដាច់ស្រយាល មិនបាន ទទួលព័ត៌មាន និងជំនាញគ្រប់គ្រាន់ក្នុងការថែរក្សាខ្លួនរបស់ពួកគេ និងទារក។ ប៉ុន្តែរឿងនេះបានត្រូវច្រាលចោលដោយលោកស្រីសុផាណារ៉ា ។

លោកស្រីបានមានប្រសាសន៍ថា បើយោងទៅតាមការអង្កេតមួយរបស់អង្គការយូអេនអេហ្វភី-អេ ដែលបានធ្វើកាលពីពេលថ្មីៗកន្លងទៅនេះ បានឱ្យដឹងថា ការយល់ដឹងរបស់ស្ត្រីកម្ពុជាពីការថែរក្សាគភ៌មានរហូតដល់ទៅដល់ ៨០% សម្រាប់ស្ត្រីទាំងអស់ទៅហើយ ទាំងនៅទីជនបទ និងទីក្រុង។ ប៉ុន្តែបញ្ហាដែលធ្វើឱ្យអត្រាមរណមាតានៅតែខ្ពស់នោះ គឺដោយសារកង្វះខាតមន្ទីរពេទ្យនៅជិតពួកគេ។

លោកស្រីក៏បានបញ្ជាក់ថា: "ខ្ញុំមិនមានតួលេខបញ្ជាក់ច្បាស់ទេ។ តែខ្ញុំឃើញថា អត្រាមរណភាពទារកគឺមានការថយចុះច្រើន។ ប៉ុន្តែយើងនៅមានបញ្ហាអត្រាមរណភាពមាតានៅខ្ពស់ដដែល ហើយការថយចុះគឺតិចតួចណាស់ ដោយសារស្ត្រីជាច្រើននៅតំបន់ជនបទគាត់មិនអាចទៅមន្ទីរពេទ្យបានពីព្រោះវាឆ្ងាយពីផ្ទះ ហើយគាត់ខ្វះមធ្យោបាយមកទទួលសេវាសម្រាលនៅមន្ទីរពេទ្យផងដែរ" ។

បញ្ហាដែលលោកស្រីបានលើកឡើងនេះគឺស្របគ្នានឹងយោបល់របស់ អ្នកស្រី លី ចន្ទ្រា អាយុ ៣០ ឆ្នាំ ដែលកំពុងសម្រាកសម្រាលបុត្ររបស់អ្នកស្រីនៅក្នុងមន្ទីរពេទ្យបង្អែកខេត្តកំពង់ស្ពឺ។ អ្នកស្រីលី ចន្ទ្រាដែលមានមុខរបរធ្វើស្រែ ហើយមានទីលំនៅ ភូមិអាងស្រណំ ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ ក៏បានឱ្យ ដឹងថា គាត់និងគ្រួសារបានចំណាយពេលរហូតដល់ទៅមួយថ្ងៃពេញដើម្បីធ្វើដំណើរមកកាន់មន្ទីរពេទ្យ បង្អែកខេត្តនេះ ក្រោយពេលដែលគាត់ធ្លាក់ឈាម ហើយត្រូវសម្រាលកូនមុនកំណត់។ បងស្រីបានឱ្យ ដឹងទៀតថា គាត់ធ្លាប់ទទួលព័ត៌មានតាមវិទ្យុ និងទូរទស្សន៍ណែនាំស្ត្រីដែលមានផ្ទៃពោះមកពិនិត្យសុខភាព និងទទួលថ្នាំជាតិដែកនៅមណ្ឌលសុខភាព ដែរ។ ប៉ុន្តែដោយហេតុថា មណ្ឌលសុខភាពស្ថិតនៅឆ្ងាយពីផ្ទះពេក និងពិបាកធ្វើដំណើរ ហើយណាមួយ គាត់ធ្លាប់មានកូន ៣ស្រីនាក់មកហើយ គឺអត់ដែលកើតបញ្ហាអីនោះ ក៏ចេះតែធ្វើហ៊ីៗទៅ ហើយក៏មិន បានមកមណ្ឌលសុខភាព។

បងស្រីចន្ទ្រា បានបញ្ជាក់ថា: "កាលកូនបីមុនខ្ញុំ សម្រាលនៅតែផ្ទះ ប៉ុន្តែមិនដែលមានបញ្ហាអ្វី។ ដល់អាពៅ ក៏ចេះតែហ៊ីៗ ទៀត។ ប៉ុន្តែវាបានត្រឹមតែ៧ខែ ស្រាប់តែខ្ញុំធ្លាក់ឈាមទើបរត់មកពេទ្យ។ ពេទ្យថា សុខបាំងមុខស្បូន ប៉ុន្តែកូននឹងកើត" ។

បន្ទាប់ពីការជួយសង្គ្រោះរបស់ក្រុមគ្រូពេទ្យនៃមន្ទីរពេទ្យបង្អែកខេត្តកំពង់ស្ពឺ បងស្រីបានសម្រាលបានកូនប្រុសមួយរូបដែលមានសុខភាពប្រក្រតី បើ ទោះបីជាគេមិនទាន់គ្រប់ខែក៏ដោយ។

លោកព្រំ សុភី ប្រជាជនក្នុងខេត្តកំពង់ស្ពឺ ដែល កំពុងនាំកូនអាយុ ២ខែ មកទទួលយកថ្នាំបង្ការនៅមណ្ឌលសុខភាពនៅជាប់មន្ទីរពេទ្យបង្អែកនៃខេត្តកំពង់ស្ពឺ ក៏បានប្រាប់ថា ភរិយាគាត់អាចបង្កើតកូនប្រុសម្នាក់ មានសុខភាពបរិបូរ និងគ្មានគ្រោះថ្នាក់ ពីព្រោះពួកគាត់តែងមកពិនិត្យសុខភាព និងទទួលថ្នាំជាតិដែកនៅមណ្ឌលសុខភាពជារៀងរាល់ខែ។

បងប្រុសបានបញ្ជាក់ថា : "បើកុំតែខ្ញុំនាំប្រពន្ធខ្ញុំ និងកូនខ្ញុំមកកាន់មន្ទីរពេទ្យជាប្រចាំនោះ គឺពួកគេ

## សមាគមឆ្មបកម្ពុជា

លោកស្រីអ៊ូ សារឿន ប្រធានសមាគមឆ្មបកម្ពុជា បានមានប្រសាសន៍ថា សមាគមនេះបានចាប់កំណើតឡើងក្នុងគោលបំណងពង្រឹងវិជ្ជាជីវៈលក្ខណៈសម្បត្តិ និងគុណសម្បត្តិរបស់ឆ្មបដើម្បីកាត់បន្ថយគ្រោះថ្នាក់ដល់ស្ត្រី និងទារកនៅក្នុងពេលសម្រាល។ លោកស្រីបានឱ្យដឹងថា សមាគមនេះបានបង្កើតឡើងតាំងតែពីឆ្នាំ១៩៩៤មក ហើយមកដល់ពេលនេះ មានសមាជិកជាឆ្មបទាំងអស់ចំនួន២០០០នាក់។

សមាគមនេះបង្កើតឡើងក្រោមគំនិតផ្តួចផ្តើមរបស់ក្រសួងសុខាភិបាលដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងអភិវឌ្ឍន៍ធនធានមនុស្សផ្នែកឆ្មបនៅកម្ពុជា។ នៅក្នុងប្រទេសកម្ពុជា នាពេលបច្ចុប្បន្ននេះ មានឆ្មបទាំងអស់ចំនួនប្រមាណជា ៣៣០០នាក់ កំពុងតែធ្វើការនៅតាមមន្ទីរពេទ្យ និងមណ្ឌលសុខភាពនៅទូទាំងប្រទេស។ ឆ្មបនៅកម្ពុជាមានពីរកម្រិត គឺឆ្មបមធ្យម និងឆ្មបបឋម។ ឆ្មបមធ្យមមានជាង ១៨០០នាក់ ហើយក្រៅពីនោះគឺជាឆ្មបបឋម។

លោកស្រីអ៊ូ សារឿន បានឱ្យដឹងដែរថា តាមការរំពឹងទុកសមាជិកភាពរបស់សមាគមឆ្មបកម្ពុជានឹងពង្រីកបន្ថែមទៀតនៅក្នុងឆ្នាំនេះ។

# ព័ត៌មានព្រះសហគមន៍កាតូលិក

## ទាំងអស់គ្នាចូលរួមទប់ស្កាត់ការជួញដូរស្ត្រី និងកុមារ

**ជាត សំភី**

នៅថ្ងៃទី៨ ខែកញ្ញា អង្គការការីតាសបានរៀបចំកម្មវិធីអប់រំតាមរយៈការសម្តែងរឿងពីការជួញដូរមនុស្សនៅភូមិព្រះធាតុ ឃុំរលួស ស្រុកកណ្តាល ស្ទឹង ខេត្តកណ្តាល ដោយផ្តោតជាសំខាន់ទៅលើរូប ភាពនៃការជួញដូរស្ត្រី និងកុមារ។

សាច់រឿងនិយាយអំពីភាពក្រីក្រដែលជំរុញឱ្យឪពុកម្តាយសុខចិត្តផ្ញើកូនស្រីឱ្យនៅនឹងគេជាថ្នូរនឹងលុយកាក់។ កូនស្រីនោះមិនបានរៀនសូត្រ ទទួល ការរំលោភបំពានផ្លូវភេទពីម្ចាស់ផ្ទះ និង-ចាញ់បោក មិត្តភក្តិរហូតដល់ធ្លាក់ខ្លួនធ្វើជានារីពេស្យាចារ្យ។ ឈុតមួយទៀតរៀបរាប់ពីការលើកកូនឱ្យរៀបការជាមួយនិងអាណិកជនដែលគាត់គ្មានប្រវត្តិច្បាស់លាស់។ ហើយអាណិកជននោះក៏យកកូនក្រមុំទៅលក់ឱ្យថៅកែដើម្បីបម្រើកាមគុណ។

អ្នកមកចូលរួមទស្សនា គឺប្រជាជនដែលជាសមាជិករបស់កម្មវិធីអភិវឌ្ឍន៍សហគមន៍នៃអង្គការ ការីតាស។ ពួកគាត់មានគ្នាចំនួន ៦០នាក់ ព្រមទាំង អ្នកតំណាងឱ្យអាជ្ញាធរភូមិ-ឃុំផងដែរ។ ចំណែកអ្នកសម្តែងគឺជាក្រុមយុវជនដែលមកពីកម្មវិធីអ-ភិវឌ្ឍន៍យុវជននៃអង្គការការីតាស។

កញ្ញាង៉ៃ សុមាលា មន្ត្រីទំនាក់ទំនងនៃអង្គការការីតាសនិយាយថា កម្មវិធីនេះធ្វើឡើងក្នុងគោលបំណងទីមួយ យើងចង់ផ្តល់ឱកាសដល់យុវជនដែលមកពីកម្មវិធីអភិវឌ្ឍន៍យុវជននៃអង្គការការីតាស



Photo : P. Samphy

ប្រជាជនអបអរនឹងឈុតសម្តែងរឿងអប់រំអំពីការជួញដូរស្ត្រី និងកុមារ ដែលរៀបចំដោយអង្គការការីតាស

## សិក្ខាសាលាស្តីអំពីវប្បធម៌លើផ្នែករបាំបុរាណខ្មែរ



Photo : Y. Mary

កាលពីថ្ងៃទី២៣-២៥កញ្ញា កន្លងទៅនេះ នៅព្រះសហគមន៍បាត់ដំបង មានរៀបចំសិក្ខាសាលាជាលើកដំបូងស្តីពីវប្បធម៌ផ្នែករបាំបុរាណខ្មែរ និងការ បង្កើតរបាំថ្មី ក្រោមការណែនាំពីកញ្ញាសួន ប៊ុណ្ណា-រ៉េតជាអ្នកគ្រូរបាំ ព្រមទាំងមានការចូលរួមគាំទ្រពីលោកអភិបាលភូមិភាគបាត់ដំបង អេនរីកេ ហ្វីកា- រេដូ លោកឪពុកតូទិត បងស្រីអាត រួមនិងសិល្បករ សិល្បការិនីមកពីបណ្តាព្រះសហគមន៍នានាទាំងបីភូមិភាគប្រមាណជា ៩០នាក់។

កញ្ញាសួន ប៊ុណ្ណារ៉េត និយាយថា : "សិក្ខាសាលា នេះបានបង្កើតឡើងដើម្បីឱ្យសិល្បករ សិល្បការិនី ជំនាន់ក្រោយដែលបានបន្ត និងកំពុងហាត់រៀនរបាំ បុរាណ និងរបាំប្រជាប្រិយខ្មែរ នៅតាមព្រះសហគមន៍នានា បានស្វែងយល់ឱ្យកាន់តែស៊ីជម្រៅពីរបាំ ខ្មែរ ដែលត្រូវការនូវក្បួនខ្នាត និងបែបបទសិល្បៈបុរាណដែលដូនតាខ្មែរបានបន្សល់ទុក។ នេះជៀសវាងនូវការបង្ហាត់តៗគ្នា ដោយគ្មានក្បួនខ្នាតច្បាស់ លាស់ ដែលធ្វើប៉ះពាល់ដល់វប្បធម៌របាំបុរាណ"។

## សន្និបាតយុវជនយុវនារីភូមិភាគភ្នំពេញអំពីឆ្នាំបូជាចារ្យ

ពីថ្ងៃទី០៧-១១ កញ្ញា នៅសាលាបច្ចេកទេស ដុនបូស្កូ ភ្នំពេញថ្មី មានរៀបចំធ្វើសន្និបាតយុវជនយុវនារីភូមិភាគភ្នំពេញ ប្រចាំឆ្នាំ២០០៩ ក្រោមប្រធានបទ: "តើព្រះជាម្ចាស់ត្រាស់ហៅខ្ញុំ ឱ្យធ្វើអ្វីក្នុងព្រះសហគមន៍ ?" ដែលមានយុវជនយុវនារី ៣៥០នាក់ ចូលរួម ក្នុងនោះក៏មានគណៈកម្មការ ចំនួន ៣០នាក់ផងដែរ។

លោកបូជាចារ្យស៊ីប្រាមុង វីរជ័យ ទទួលខុស ត្រូវនៅព្រះសហគមន៍ក្រុងព្រះសីហនុ បានមាន ប្រសាសន៍ថា : "ឆ្នាំនេះគឺជាឆ្នាំបូជាចារ្យ។ យើងបានលើកយកប្រធានបទខាងលើនេះមកគឺដើម្បីឱ្យយុវជនយុវនារីទាំងអស់ រិះគិតជាមួយគ្នាអំពីការត្រាស់ហៅរបស់ព្រះជាម្ចាស់ក្នុងការទទួលមុខងារជាបូជាចារ្យ បងប្រុស បងស្រីគ្រូអប់រំជំនឿ និងមុខងារផ្សេងៗទៀតដើម្បីជំរុញឱ្យព្រះសហ-គមន៍កាន់តែរីកចម្រើនឡើង"។

លោកផុន សុផល អ្នកទទួលខុសត្រូវការិយា- ល័យយុវជន និងកុមារភូមិភាគភ្នំពេញ និយាយ ថា ក្រៅអំពីសម្មភាពផ្សេងៗ ដែលណែនាំយុវជនយុវនារីឱ្យចេះរិះគិត អំពីឆ្នាំបូជាចារ្យ និងការរួប រួមគ្នាកសាងព្រះសហគមន៍ឱ្យកាន់តែរីកចម្រើន

October-2009:October-2009.qxd 11/06/2010 16:42 Page 13



# សម្ពោធមណ្ឌលអ្នកជំងឺសម្រាកព្យាបាល

**យឹម ម៉ារី**

កាលថ្ងៃទី១៣ កញ្ញា មានពិធីសម្ពោធមណ្ឌលសម្រាកព្យាបាលអ្នកជំងឺថ្មីមួយ ឈ្មោះថា អេលី-សាប៉ែត នៅក្រោមការផ្តួចផ្តើមបង្កើតរបស់គណៈកម្មការ៥រូប និងលោកបូជាចារ្យម៉ារីយូ អ្នកទទួលខុសត្រូវព្រះសហគមន៍ព្រះកុមារយេស៊ូបឹងទំពុន ទីក្រុងភ្នំពេញ។ នៅក្នុងពិធីគ្រីស្តបរិស័ទបានចូលរួម ប្រហែល២០០នាក់ និងមានការអញ្ជើញជាអធិបតីភាពពីលោកអភិបាលអេមីល ដេតម្បូ។

បងស្រីប៉ោឡា ម៉ាយូគី ប្រធានមណ្ឌលសុខភាព អេលីសាប៉ែតនេះ បានមានប្រសាសន៍ថា : "យើងទទួលអ្នកជំងឺទីទាល់ក្រ ដែលបញ្ជូនមកតាមរយៈ ព្រះសហគមន៍នានាទាំងបីភូមិភាគ ឱ្យសម្រាកធ្វើ ការព្យាបាលជំងឺទូទៅ ពិសេសជំងឺមហារីក តែម្តង ដែលការព្យាបាលត្រូវចំណាយថវិកាជាច្រើន និងដើម្បីឱ្យដំណើរការល្អ យើងបានសហប្រតិបត្តិការ ឬភ្ជាប់ទំនាក់ទំនងជាមួយមន្ទីរពេទ្យមួយចំនួន ដូច ជាមន្ទីរពេទ្យរុស្ស៊ី និងពេទ្យលោកសង្ឃជាដើម"។



Photo : L. Sovanna

លោកអភិបាលប្រសិទ្ធពរដល់មណ្ឌលអេលីសាប៉ែត

បើតាមប្រសាសន៍របស់លោកបូជាចារ្យម៉ារីយូ ហ្គេស្សីបានឱ្យដឹងថា មណ្ឌលសុខភាពថ្មីអាចទទួល អ្នកជំងឺឱ្យសម្រាកព្យាបាលបាល ចំនួន១៧នាក់។ ជំនួយឧបត្ថម្ភក្នុងការសាងសង់ និងថវិកា

# ដំណើរទស្សនកិច្ចសិក្សានៅប្រទេសបារាំង

សិស្សានុសិស្ស និងគ្រូ ចំនួន១៥នាក់ នៃវិទ្យាល័យសន្តហ្វ្រង់ស័រនៅក្នុងភូមិចំការទៀង ឃុំគួស ស្រុកត្រាំកក់ ខេត្តតាកែវ ដឹកនាំដោយលោកបូ-ជាចារ្យអូលីវីយេបានទៅធ្វើទស្សនកិច្ចសិក្សានៅ តាមសាលាជាដៃគូនានានៅប្រទេសបារាំង កាល ពីថ្ងៃទី៧ ខែកញ្ញា កន្លងទៅ។

សម្រាប់គោលបំណងនៃដំណើរទស្សនកិច្ចនេះ លោកប៉ិច វិបុល នាយកវិទ្យាល័យ បានឱ្យដឹង-មុន ពេលចេញដំណើរថា នេះគឺជាទស្សនកិច្ចដើម្បីធ្វើការផ្លាស់ប្តូររាល់បទពិសោធន៍គ្នាទៅវិញទៅមករវាងសាលាទាំងនេះទៅលើបច្ចេកទេសការអប់រំ កម្មវិធីសិក្សា និងរបៀបចាត់ចែង-គ្រប់គ្រង ផង ដែរ ជាងនេះទៅក៏ដើម្បីផ្តល់ឱកាសដល់សិស្សនៃសាលានីមួយៗបានធ្វើការសិក្សាអំពីវប្បធម៌រវាង ប្រទេសទាំងពីរគឺកម្ពុជា និងបារាំង។ សូមបញ្ជាក់ ថា កន្លងមកសាលាវិទ្យាល័យសន្តហ្វ្រង់ស្វ័រក៏ធ្លាប់ធ្វើទស្សនកិច្ចទៅកាន់សាលាជាដៃគូរបស់ខ្លួនដូចជានៅជប៉ុន និងសិង្ហបុរី និងក៏បានទទួលនូវដំណើរទស្សនកិច្ចរបស់សាលាទាំងនោះវិញដែរ។

សព្វថ្ងៃនេះ វិទ្យាល័យសន្តហ្វ្រង់ស័រជាសាលា



សិស្សានុសិស្ស សាលាសន្តហ្វ្រង់ស្វ័រ

# ព្រះសហគមន៍អាស៊ាន ជួបពិភាក្សាអំពីពិធីបុណ្យ

ពីថ្ងៃទី១៦ ដល់ថ្ងៃទី២១ ខែកញ្ញាកន្លងទៅនេះ តំណាងព្រះសហគមន៍នៃប្រជាជាតិអាស៊ីអាគ្នេយ៍ បានមកជួបប្រជុំគ្នានៅទីក្រុងម៉ាកាទី ប្រទេសហ្វី- លីពីន ដើម្បីពិភាក្សា និងចែករំលែកបទពិសោធន៍ នៅលើប្រធានបទ "ឆ្នាំនៃពិធីបុណ្យ និងការបញ្ចូល វប្បធម៌"។ នេះគឺជាលើកទី១៣ ហើយដែលក្រុម នេះ បានជួបជុំគ្នា និងក៏បានពិភាក្សាលើប្រធានបទផ្សេងៗ អំពីពិធីបុណ្យដោយផ្សារភ្ជាប់ទៅនឹងវប្ប- ធម៌។ តួយ៉ាងនាឆ្នាំ២០០៧ គេពិភាក្សាលើប្រធានបទ "ការប្រារព្ធពិធីបុណ្យនៅថ្ងៃអាទិត្យ"។ នៅឆ្នាំ ២០០៨លើប្រធានបទ "ការប្រារព្ធពិធីបុណ្យអគ្គ-សញ្ញាអាពាហ៍ពិពាហ៍"។

សម្រាប់កិច្ចប្រជុំពិភាក្សាលើកនេះ មានសមា- ជិក ៤៧នាក់ មកពីប្រទេសក្នុងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ រួមមានកម្ពុជា ប្រ៊ុយណេ ឥណ្ឌូនេស៊ី ម៉ាឡេស៊ី ហ្វីលីពីន សិង្ហបុរី ថៃ និងប្រទេសវៀត- ណាម ហើយប្រទេសអូស្ត្រាលី និងកោះតៃវ៉ាន់ ជា សមាជិកកិត្តិយស។

នាចុងបញ្ចប់នៃកិច្ចប្រជុំនេះ

October-2009:October-2009.qxd 11/06/2010 16:42 Page 14



# ពិធីបុណ្យភ្ជុំនៅព្រះសហគមន៍កាតូលិកភូមិថ្មី ភូមិភាគកំពង់ចាម

**អេគ្យេន ឡូវ៉ែយែរ**

*គ្រីស្តបរិស័ទកាតូលិកនៃព្រះសហគមន៍ ភូមិថ្មី នៅភូមិភាគកាតូលិកកំពង់ចាមបាន ជួបជុំគ្នាកាល ពីថ្ងៃអាទិត្យ ទី២០ កញ្ញា*



ឈើឆ្កាងក្រដាសដាក់ឈ្មោះបុព្វការីដើម្បីប្រាប់ដល់ព្រះជាម្ចាស់



លោកបូជាចារ្យហ្វ្រង់ស្វ័រ ហេម៉េលស្តាអែល ក្នុងឱកាលកាលបើកពិធីអភិបូជានៅព្រះសហគមន៍ភូមិថ្មីភូមិភាគកំពង់ចាម



ការបរិភោគអាហាររួមគ្នាជាភាតរភាពនៅក្នុងពិធីបុណ្យរបស់គ្រីស្តបរិស័ទភូមិថ្មី និងអ្នកទូទៅដោយមិនមានការប្រកាន់




យុវជនព្រះសហគមន៍ភូមិថ្មីសម្តែងឈុតកាយវិការតាមព្រះគម្ពីរអំពីការមានព្រះជន្មឡើងវិញដ៏រុងរឿងរបស់ព្រះគ្រីស្ត



កុមារនៅក្នុងភូមិចូលរួម រីករាយ និងចូលចិត្តយ៉ាងខ្លាំង ចំពោះពិធីបុណ្យនៅព្រះវិហារព្រះសហគមន៍កាតូលិកភូមិថ្មី



ក្រុមរបាំងប្រពៃណី

October-2009:October-2009.qxd 11/06/2010 16:42 Page 15



# អក្ខរកម្មភាសាខ្មែរជួយជនជាតិភាគតិចវៀតណាម

**លី សុវណ្ណា**

ព្រះសហគមន៍កាតូលិកកោះនរា ជាព្រះសហគមន៍កាតូលិកវៀតណាម ដែលស្ថិតនៅ ៨គម ភាគ ខាងកើតទីក្រុងភ្នំពេញ នៅតាមបណ្តោយដងទន្លេ មេគង្គ។ ព្រះសហគមន៍នេះបានផ្តល់ឱកាសឱ្យដល់កញ្ញាសុខ ស្រីងៃ អាយុ១៥ឆ្នាំ អាចសិក្សា និងរៀន សូត្រអស់រយៈពេលជាច្រើនឆ្នាំរហូតដល់នាងអាចអាន និងសរសេរភាសាខ្មែរ។

មិនត្រឹមតែស្រីងៃទេ សិស្សជនជាតិវៀតណាម ផ្សេងទៀតក៏ទទួលឱកាសដូចគ្នានេះដែរ។ ចាន់ថា អាយុ១០ឆ្នាំ ដែលកំពុងរៀន ចង់ចេះអាន និងសរ-សេរអក្សរខ្មែរជាខ្លាំង។ រូបគេចង់ធ្វើជាម្ចាស់ក្រុមហ៊ុនសំណង់ផ្ទាល់ខ្លួននៅពេលរូបគេធំឡើង។

នៅពេលអ្នកសារព័ត៌មានចុះទៅជួបក្មេងៗ នាពេលថ្មីៗនេះ ការបញ្ចេញសម្លេងអក្ខរក្រម ភាសាខ្មែររបស់ពួកគេបានលាន់ឮនៅក្នុងថ្នាក់រៀន។ នៅ បន្ទប់មួយ ក្មេងត្រូវបែងចែកជាពីរថ្នាក់ផ្សេងគ្នា។

បើតាមអ្នកគ្រូលី រ័ត្ននា បានឱ្យដឹងថា ក្មេងៗនៅចន្លោះអាយុពី៦ ទៅដល់១២ឆ្នាំ ចំនួន ៤៤នាក់ រៀននៅថ្នាក់ទី១ ហើយពីអាយុ ១៣ឆ្នាំ ដល់អាយុ ១៦ឆ្នាំ មានចំនួន ១០នាក់ រៀននៅថ្នាក់ទី២។

អ្នកគ្រូរ័ត្ននា អាយុ២៥ឆ្នាំ បានបន្តថា ខ្ញុំជួបការ លំបាកយ៉ាងខ្លាំង នៅពេលបង្រៀនថ្នាក់ពីរផ្សេងគ្នា ក្នុងបន្ទប់តែមួយ និងនៅពេលតែមួយ។ នៅពេលខ្ញុំចាប់ផ្តើមបង្រៀនសិស្សថ្នាក់ទីមួយ ខ្ញុំដាក់កិច្ចការ ឱ្យសិស្សថ្នាក់ទីពីរធ្វើដែរ។

លោកលី សុធា ជាអ្នកចាត់ចែងកម្មវិធីអក្ខរកម្ម ភាសាខ្មែរ សម្រាប់ព្រះសហគមន៍វៀតណាម ក្នុងភូមិភាគភ្នំពេញ ក៏មានប្រសាសន៍ថា កម្មវិធីអក្ខរ-កម្មភាសាខ្មែរដំណើរនៅព្រះសហគមន៍វៀតណាម ចំនួន ១៥។ កម្មវិធីនេះបានចាប់ផ្តើមនៅឆ្នាំ១៩៩៥ នៅព្រះសហគមន៍កោះនរា ដោយបង្រៀន ក្មេងៗវៀតណាម មុនពេលពួកគេទៅសាលារដ្ឋ។ សិស្សជាច្រើនបានបន្តការសិក្សារហូតដល់ថ្នាក់ទី៦ ហើយ អ្នកខ្លះបានបោះបង់ការសិក្សាចោល។ ខ្លះមករៀន នៅថ្នាក់ចាស់វិញ ដោយសារពួកគេតាមមិនទាន់។

លោកគ្រូសុធាបានបន្តថា ព្រះសហគមន៍វៀត-ណាមជាសហគមន៍ក្រីក្រ ហើយពួកគេចិញ្ចឹមជីវិត ដោយការនេសាទ ធ្វើការសំណង់ រើសសំរាម ដេរ ស្បែកជើង និងរកស៊ីលក់ដូរកំប៉ិកកំប៉ុក។ រីឯក្មេងៗត្រូវខិតខំរកលុយដើម្បីផ្គត់ផ្គង់ជីវភាពគ្រួសារ។

ដូច្នេះជួនកាលព្រះសហគមន៍ក៏មិនអាចបង្រៀនក្មេងៗទាំងនោះបានជាពិសេសនៅរដូវនេសាទ។

លោកគ្រូសុធាបានសង្កត់ធ្ងន់ថា សមត្ថភាពចេះ អាន និងសរសេរភាសាខ្មែរ គឺជាមូលដ្ឋានគ្រឹះដើម្បី សិក្សា



Photos : P. Samphy

## ជីវិត

# បងស្រីម៉ារី ព្រីម៉ា ប្រធានថ្មីក្រុមបងស្រីមេត្តាករុណាមកកម្ពុជា

**លី សុវណ្ណា**



Photo : L. Sovanna

បងស្រីម៉ារី ព្រីម៉ា ដែលជាប្រធានថ្មីរបស់ក្រុម បងស្រីមេត្តាករុណា ដែលបន្តមុខងារអំពីអ្នកម្ដាយតេរេសានៃក្រុងកាល់គុលថា ប្រទេសឥណ្ឌា បានមកធ្វើទស្សនកិច្ចនៅប្រទេសកម្ពុជានៅរយៈពេលមួយ សប្ដាហ៏កាលពីចុងខែកញ្ញាកន្លងទៅ។

ក្នុងដំណើរទស្សនកិច្ចនេះ បងស្រីប្រធានក៏បាន ចាប់អារម្មណ៏ថា ព្រះសហគមន៍កាតូលិកនៅកម្ពុជា មានការរីកចម្រើនយ៉ាងខ្លាំងបន្ទាប់ពីបានចាប់ផ្ដើម ឡើងវិញក្រោយសង្គ្រាមស៊ីវិល។ បងស្រីបានមាន អំណរផងដែរ ដែលបានមើលឃើញ និងការគាំទ្រពីព្រះសហគមន៏នៅកម្ពុជាចំពោះសកម្មភាពរបស់ក្រុមបងស្រីមេត្តាករុណា និងជាងនេះទៅទៀត គឺមើលឃើញបងប្អូន អ្នកក្រីក្រ ដែលសុខចិត្តទទួលនូវការបម្រើរបស់ក្រុមបងស្រីសម្រាប់គេ។ ពេល ត្រឡប់ទៅវិញប្រទេសឥណ្ឌាវិញ បងស្រីបន្តអធិ-ដ្ឋានសម្រាប់ព្រះសហគមន៏នៅកម្ពុជាឱ្យពោរពេញ ដោយការរីកចម្រើន និងសេចក្ដីសង្ឃឹមដែរ។

បងស្រីប្រធាន ក៏បានបន្តថា ក្រុមបងស្រីមេត្តាករុណាបានមកដល់ព្រះរាជាណាចក្រកម្ពុជានៅឆ្នាំ ១៩៩១ ក្រោយមានការអញ្ជើញពីសម្ដេចនាយករដ្ឋមន្ត្រី នៅពេលលោកធ្វើទស្សនកិច្ច នៅប្រទេសឥណ្ឌា និងក៏ដូចជាការអញ្ជើញមករបស់លោកអភិ-បាល ព្រះសហគមន៏កម្ពុជានៅពេលនោះផងដែរ។

សព្វថ្ងៃបងស្រីមានមណ្ឌលចំនួនបីកន្លែង។ នៅ ភ្នំពេញមានពីរ និងនៅសៀមរាបមានមួយកន្លែង។

សកម្មភាពរបស់មណ្ឌលទាំងនេះ គឺមានទទួលថែរក្សាក្មេងៗកំព្រា អ្នកជំងឺរបេង អ្នកផ្ទុកមេរោគ អេដស៏ និងអ្នកជំងឺអេដស៏ ព្រមទាំងមានការចែក ថ្នាំ និងពិនិត្យជំងឺជារៀងរាល់ថ្ងៃសៅរ៍ នៅមណ្ឌលមុនីវង្ស និងចោមចៅ នៅភ្នំពេញ ជាមួយគ្រូពេទ្យជំនាញ។ ទន្ទឹមគ្នានេះ ក៏មាននៅបើកថ្នាក់បង្រៀនកុមារក្រីក្រនូវអក្សរសាស្ត្រខ្មែរផងដែរ។

នៅក្នុងពិភពលោក ក្រុមបងស្រីមានសមាជិក ៤៩៥០នាក់ ក្នុងប្រទេសចំនួន១៣៦ និង-មាន៧៦៦ មណ្ឌល។ ក្រុមបងស្រីតែងបន្តគោលការណ៏នៃការអប់រំនៃអ្នកម្ដាយតេរេសា "រស់នៅជាអ្នកក្រីក្រក្នុង ចំណោមអ្នកក្រីក្រ"

## ប្រតិទិនអភិបូជា

- **ភាសាខ្មែរ** : ព្រះវិហារសន្តយ៉ូសែបភ្នំពេញ (០១២ ៧៨២ ២៤១) ថ្ងៃច័ន្ទ-សៅរ៍ : ព្រឹកម៉ោង៦។ ថ្ងៃអាទិត្យ : ម៉ោង ៨ព្រឹក និងម៉ោង៤រសៀល។
-កំពង់សោម (០១៦ ៨៤០ ៥៤០) ថ្ងៃច័ន្ទ ថ្ងៃពុធ និងថ្ងៃសុក្រ : ល្ងាចម៉ោង៥។ ថ្ងៃអង្គារ ថ្ងៃព្រហស្បតិ៍ និងថ្ងៃសៅរ៍ : ព្រឹកម៉ោង៦។ ថ្ងៃអាទិត្យ : ម៉ោង ៨ព្រឹក។
-សៀមរាប (០៦៣ ៩៦៥ ២៨០) ថ្ងៃអាទិត្យ : ម៉ោង៧:៣០ព្រឹក។ ថ្ងៃច័ន្ទ-ថ្ងៃព្រហស្បតិ៍ : ព្រឹក ៦:៣០ម៉ោង។ ថ្ងៃសុក្រ : ម៉ោង ៦:៣០ល្ងាច។
-បាត់ដំបង (ពេទ្យយាយជី) ថ្ងៃអាទិត្យ : ម៉ោង ៨:០០ព្រឹក។ ថ្ងៃច័ន្ទ : ល្ងាច៦:០០។ ថ្ងៃអង្គារ-សុក្រ : ម៉ោង៦:១៥ ព្រឹក។
- **Français** : 1er et 3ème Samedi du mois à 5:30pm ; 2ème et 4ème Dimanche du mois à 11:00am; à l'église de St. Joseph, #1788B, RN5, PP.
- **English** : - Phnom Penh : Sunday at 10: 00 am; at St. Joseph Church (#1788B, NR5, PP); Saturday at 5: 00 pm, at World Vision Cambodia (#2 St 71, PP); - Sihaknouk Ville : Sunday at 5:00 pm; # Catholic Church St.12 13 Mattapheap; H/P: 016 840 540 (Fr. Werachai); - Siem Reap : Saturday at 6:30 pm; #Catholic Church, No 027 East River Side Street. - Battambang : Saturday: at 6:00 pm at Battamabang Church (Pet Yeaychi), Rumchek 1, Rattanak, H/P: 012 911 147 (Fr. Totet).

October-2009:October-2009.qxd 11/06/2010 16:42 Page 17







Photo : S. Philong

# មជ្ឈមណ្ឌលវប្បធម៌បារាំងរៀបចំពិព័រណ៍របាំងមុខខ្មែរ

**ខាន់ ភិរម្យ**

របាំងមុខខ្មែរដែលគេតែងឃើញសិល្បករ សិល្បការិនីសម្ដែងតែងតែជូនទស្សនិកជនទស្សនា ជាបន្តបន្ទាប់រហូតដល់សព្វថ្ងៃ នេះបានត្រូវមជ្ឈមណ្ឌលបារាំងនៅទីក្រុងភ្នំពេញរៀបចំតាំងពិព័រណ៍ជូនឱ្យភ្ញៀវជាតិ និងអន្តរជាតិទស្សនាដោយសេរីចាប់តាំងពី ពាក់កណ្ដាលខែកញ្ញា កន្លងទៅនេះ។

យោងទៅតាមសេចក្ដីប្រកាសព័ត៌មានមួយរបស់មជ្ឈមណ្ឌលវប្បធម៌បារាំងបានឱ្យដឹងថា ពិព័រណ៍របាំងមុខនេះនឹងត្រូវដាក់តាំងបង្ហាញជាសាធារណៈអំឡុងរយៈពេល ៣សប្ដាហ៍។ របាំងមុខដែលគេយកមកតាំងទាំងអស់នោះជារបាំងមុខដែលសិល្បៈករ និងសិល្បការិនីខ្មែរយកមកប្រើប្រាស់នៅក្នុងល្ខោនរឿងរាមកេរ្តិ៍។

របាំងមុខទាំងអស់នេះបានផលិតឡើងដោយលោកអន សុខ ដែលជាសាស្ត្រាចារ្យនៃសកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ និង ក្រុមគ្រួសាររបស់គាត់។

របាំងមុខដែលត្រូវបានគេយកមកតាំង នេះ គឺមានរូបផ្សេងៗពីគ្នាដូចជា មុខយក្ស ទេវតា តាឥសី មុដ និងស្វាជាដើម។

យោងតាមការអះអាងរបស់លោកអន សុខ របាំងមុខទាំងនេះ លោក និងគ្រួសារបានផលិតឡើង ដើម្បីបង្ហាញអំពីភ័ស្តុតាង និងប្រពៃណីយ៉ាងថ្លៃថ្នូររបស់បុព្វបុរសខ្មែរ ដែលបានបន្សល់ទុកតាំងពីយូរយាណាស់មកហើយ។ សព្វថ្ងៃលោក និងក្រុមគ្រួសារ របស់លោកនៅតែចេះផលិតស្នាដៃសិល្បៈបែបនេះដោយសារតែចំណេះដឹងដែលបានផ្ទេរពីជំនាន់មួយទៅជំនាន់មួយ ដែលមានរាប់សិបជំនាន់មកហើយ។

លោកក៏បានបន្តទៀតថា របាំងមុខទាំង នេះ គឺជានិមិត្តរូបសំខាន់ណាស់។ ជាទូទៅមុននឹងប្រើប្រាស់ ឬពាក់ដើម្បីការសម្ដែង សិល្បករ និងសិល្បការិនីទាំងអស់ ចាំបាច់ត្រូវរៀបចំពិធីសំពះគ្រូ និងសែនព្រេន។

## គេចាប់ស្ត្រីម្នាក់



នៅយប់មួយ ដោយអន់ចិត្តនឹងសង្សារដែលយកចិត្តទុកដាក់លើការងារជាងខ្លួន កន្នរីក៏ទៅមើលកុន ដើម្បីលំហែចិត្ត តែម្នាក់ឯង។ ប៉ុន្តែ នៅពេល ដែលនាងចេញពីរោងកុន វិញ នាងបានជួបនឹងរឿងកំសត់។ នាងបានឃើញមនុស្សចាស់ៗ ប្រុសស្រីពីរនាក់ គឺកំពុងដើរដោយលំបាក។ ដោយ មានចិត្តចង់ជួយពួកគេ នាងចូលក៏ទៅជួយគ្រា ហើយបាន ឡើងជិះឡានជាមួយពួកគេ។ គេឱ្យស្ករនាងញ៉ាំ... បន្ទាប់ មកនាងលែងកម្រើករួចដោយសារអស់កម្លាំងល្ហិតល្ហៃ។

នេះគឺជាប្រភេទរឿងស៊ើបអង្កេតដ៏កម្រមួយ និងពោរ ពេញទៅដោយអាថិកំបាំងចម្លែកៗ ដែលវាអាចជំរុញចិត្ត អ្នកអាន ឱ្យតាមដានថាតើអ្វីជាការពិត?

អ្នកនិពន្ធបានជ្រើសរើស យកវិធីសាស្ត្រសរសេរ ធ្វើឱ្យ អ្នកអានហាក់មានអារម្មណ៍ដូចជាស្ថិតនៅក្នុងចិត្តរបស់តួ អង្គ (រីករាយ អណ្ដែតអណ្ដូង រំជើបរំជួល ភ័យខ្លាច រន្ធត់ រំភើប និងក្លាហាន...)។



នេះជាស្នាដៃនិពន្ធរបស់លោកវង់ ធឿង ដែលត្រូវបានបោះពុម្ពជាថ្មី នៅឆ្នាំ២០០១ និងមានកម្រាស់៨៨ទំព័រ។

## ទប់ស្មារតីកុំយំ កុំសើច

ជាធម្មតា នៅពេលយើងគិត អ្វីខុសគេ ធ្វើអ្វីខុសគេ ឬនិយាយអ្វី ខុសគេ។ អ្នកផងតែងតែថា យើងជាមនុស្សឆ្កួត។ ប៉ុន្តែបើឆ្កួតដោយសារបានត្រិះរិះពិចារណា ទៅលើអ្វីដែលគេមើលពុំឃើញ ឬដែលគេខ្លាចមិនហ៊ាននិយាយ វាក៏មិនអត់ប្រយោជន៍ប៉ុន្មានទេ។ រឿងនេះគឺជាស្នាដៃរបស់ អ្នកនិពន្ធ ខាំពូនគិមនី។

មានរឿងខ្លីៗជាច្រើន ដែលនិយាយរិះគន់សង្គមដោយ បញ្ឆិតបញ្ឆៀង ដូចជា "យុត្តិធម៌?" "ឧបមាថា..." "បាញ់ សម្លាប់ទៅ" "ល្អជាងជំពោះមហារីក"...។ ការបណ្ដុះគំនិត ជាតិនិយមរួមមាន "ឱ្យតែជួយគ្រាខ្ញុំចុះ"... និងការវិភាគ

October-2009:October-2009.qxd 11/06/2010 16:42 Page 18



# ម៉ុងហ្គោលីធ្លាប់ជាចក្រភពធំបំផុតលើលោក

**ជាត សំភី**



## ភូមិសាស្ត្រនៃប្រទេសម៉ុងហ្គោលី

ប្រទេសម៉ុងហ្គោលីមានផ្ទៃដីទំហំ ១ ៥៦៥ ០០០ គម២។ ប្រទេសនេះមានប្រជាជន ២ ៩៥៦ ០៨១ (ឆ្នាំ២០០៨)។ រាជធានី : អ៊ូឡង់ បាទ័រ។ ភាសា : ខាល់ខា។ រូបិយវត្ថុ : ទូគ្រីហ្គ (Tukrig)។

ប្រទេសម៉ុងហ្គោលីមានសភាពសោះកក្រោះ នៅរដូវក្តៅ ក្តៅខ្លាំង ប៉ុន្តែរដូវរងារត្រជាក់ខ្លាំង។ នេះជាប្រទេសដែលសម្បូរដោយវាលស្មៅ តំបន់ភ្នំ ដូចជាភ្នំហ្គ្រេង់ ឃីខាន់ អាល់តៃ និងធានសាន។ ម៉ុងហ្គោលីក៏ជាប្រទេសដែលយករបរកសិកម្មចិញ្ចឹមសត្វជាអាទិភាព ជាពិសេសការចិញ្ចឹមសេះ។ ចំណែកប្រជាជនកំពុងផ្លាស់ប្តូរទម្លាប់ពីរស់នៅជាចរកជនមករស់នៅហ្នឹងមួយកន្លែងដែរ។

ម៉ុងហ្គោលី គឺជាប្រទេសមួយដែលស្ថិតនៅទ្វីបអាស៊ីកណ្តាល នៅចន្លោះប្រទេសរុស្ស៊ី និងប្រទេស ចិន។ បើតាមប្រវត្តិសាស្ត្របុរាណមានជនជាតិភាគតិចជាច្រើនមករស់នៅលើទឹកដីម៉ុងហ្គោលី ហើយ ពួកគេភាគច្រើនគឺជាចរកជនដែលរស់នៅចល័តទី កន្លែង និងជួនកាលក៏ប្រមូលផ្តុំគ្នាបានជាកុលសម្ព័ន្ធតូចធំ និងនិយាយភាសាម៉ុងហ្គោល។

នៅឆ្នាំ២៤៥ មុនគ្រិស្តសករាជ កុលសម្ព័ន្ធមួយម៉ុងហ្គោលីស្យុងញូ បានចាប់កំណើតឡើង។ ពួកគេ បានវាយលុក និងបានក្លាយជាសត្រូវរបស់ចិន នៅប៉ុន្មានសតវត្សរ៍ក្រោយមក។ ហើយមហាកំពែងដ៏ល្បីរបស់ចិនដែលបានស្ថាបនាឡើងក្នុងផ្នែកមួយក៏ដើម្បីការពារការលុកលុយរបស់ស្យុងញូនេះដែរ។ បន្ទាប់ពីកុលសម្ព័ន្ធស្យុងញូបានដួលរលំ កុលសម្ព័ន្ធជាច្រើនបានបន្តគ្នាគ្រប់គ្រងនៅម៉ុងហ្គោលី។ កុលសម្ព័ន្ធរួនរួន បានគ្រប់គ្រងតំបន់ម៉ុងហ្គោលីចាប់ពី ដំណាច់សតវត្សរ៍ទី៤ ដល់ដំណាច់សតវត្សទី៦។ ពី សតវត្សរ៍ទី១០ដល់ទី១២ កុលសម្ព័ន្ធគីតានបង្កើតរាជាណាចក្រនៅតំបន់ម៉ាន់ជូរីភាគឦសានចិន។

ឆ្នាំ ១២០៦ មេកុលសម្ព័ន្ធមួយដែលមានឈ្មោះ ថា តេមូជីន ក៏បង្រួបបង្រួមកុលសម្ព័ន្ធម៉ុងហ្គោល ទាំងអស់។ ដោយប្រកាន់យកនាម ហ្សេនហ្ស៊ី ខាន់ គាត់បានផ្តល់កំណើតចក្រភពមួយធំបំផុតមួយនៃប្រវត្តិសាស្ត្រដែលគ្របដណ្តប់ស្ទើរពេញអឺរ៉ុបអាស៊ី និងមានផ្ទៃដីប្រមាណ ៣៣លានគីឡូម៉ែត្រការេ។ ប្រទេសម៉ុងហ្គោលីសព្វថ្ងៃជាមជ្ឈមណ្ឌលកណ្តាល នៃចក្រភព។ តំបន់ជាជាច្រើនរាប់មិនអស់នៅអឺរ៉ុប មជ្ឈិមបូពា និងអាស៊ី មានជាអាទិ៍ ដូចជា ហុងគ្រី រុស្ស៊ី ស៊ីរី អ៊ីរ៉ង់ អ៊ីរ៉ាក់ ឬអាហ្គានីស្ថាន និងប្រទេសចិនស្ថិតនៅក្នុងចំណុះចក្រភពម៉ុងហ្គោលីដែរ។ ការ ច្បាំងពង្រីចក្រភពបានយ៉ាងធំគឺដោយសារកងទ័ពវង្សត្រកូលខាន់ជាអ្នករស់នៅវាលស្មៅជំនាញខាងជិះសេះជាមួយនឹងការច្បាំងតាមរបៀបព្រៃយ៉ាងរហ័សដូចផ្លេកបន្ទោរតែប្រកបដោយការបំផ្លាញ។

ចំណែកឯប្រទេសចិនក៏ត្រូវធ្លាក់នៅក្រោមការគ្រប់គ្រងរបស់ម៉ុងហ្គោលីនៅពាក់កណ្តាលទីពីរនៃន សតវត្សរ៍ទី១៣។ នេះជាសម័យរាជវង្សយ័ន Yuan ដែលដឹកនាំដោយគូប៊ីឡៃខាន់។

ចក្រភពម៉ុងហ្គោលីចាប់ផ្តើមស្រុតចុះជាមួយនិងការបាត់បង់ប្រទេសចិននៅឆ្នាំ១៣៨៦។ បន្ទាប់ ពីចក្រភពបែកបាក់ កុលសម្ព័ន្ធម៉ុងហ្គោលីបានធ្លាក់ចូលទៅក្នុងភាពអាណាធិបតេយ្យ។ នៅសតវត្សរ៍ទី១៦ នៅក្រោមរាជរបស់ស្តេចអាល់តង់ ខាន់ ជនជាតិម៉ុងហ្គោលបានប្រែមកកាន់ព្រះពុទ្ធសាសនាទី បេ។ មួយសតវត្សរ៍ក្រោយមកជនជាតិម៉ុងហ្គោលបានធ្លាក់ក្រោមការគ្រប់គ្រងរបស់ជនជាតិម៉ាន់ជូដែលយកពួកគេធ្វើជាជំនួយសម្រាប់ច្បាំងដណ្តើមយកប្រទេសចិន។ បន្ទាប់មកម៉ុងហ្គោលីក៏ក្លាយជាខេត្តចំណុះរបស់ចិនក្រោមការគ្រប់គ្រងរបស់រាជ-វង្សម៉ាន់ជូ។ បន្ទាប់ពីបដិវត្តន៍ និងមានការរើបអូសអំណាចពីអធិរាជចុងក្រោយនៃរាជវង្សម៉ាន់ជូនាម ពូយី នៅថ្ងៃទី១ ធ្នូ ឆ្នាំ១៩១១




Photos : DR

# អធិប្បាយព្រះបន្ទូលថ្ងៃអាទិត្យ

អ្នកនាំសារខែតុលា ២០០៩-ដោយលោកឪពុកខ្ញុំទសង់ សេនីយ៍ឆាល់

នៅក្នុងខែនេះ យើងស្ដាប់ព្រះបន្ទូលដែលដកស្រង់ចេញពីជំពូក១០ របស់ព្រះ គម្ពីរដំណឹងល្អតាមលោកម៉ាកុស។ ក្នុងអត្ថបទទាំងនោះ ព្រះយេស៊ូកំពុងធ្វើដំណើរ ឡើងទៅទីក្រុងយេរូសាឡឹម ហើយទ្រង់ក៏បង្រៀនសាវ័ក និងបណ្ដាជនតាមផ្លូវពី ព្រះរាជ្យនៃស្ថានបរមសុខ

### ថ្ងៃអាទិត្យទី២៧ ក្នុងរដូវធម្មតា (ថ្ងៃទី០៤ ខែតុលា ឆ្នាំ២០០៩) *ម៉ាកុស ១០,២-១៦*

នៅថ្ងៃអាទិត្យនេះ ព្រះយេស៊ូឆ្លើយសំនួរមួយរបស់គណៈផារីស៊ីពីរបៀបរស់នៅជាស្វាមី-ភរិយា ដែល ពួកគេបានសួរគ្រាន់តែក្នុងគោលបំណងល្បងមើលព្រះអង្គប៉ុណ្ណោះ។ សម័យព្រះយេស៊ូ គឺមានក្រិត្យវិន័យ មួយក្នុងធម្មវិន័យ របស់លោកម៉ូសេដែលអនុញ្ញាតឱ្យស្វាមីលែងភរិយា។ បើតាមក្រិត្យវិន័យនេះ បុរស មានសិទ្ធច្រើនជាងស្ត្រី !។ ព្រះយេស៊ូជំទាស់នឹងក្រិត្យវិន័យនេះ ហើយបញ្ជាក់ថា គូស្រករដែលរៀបការ ក្លាយទៅជាស្វាមី-ភរិយា គឺដើម្បីរស់នៅជាគូយ៉ាងស្មោះត្រង់នឹងគ្នាអស់មួយជីវិត។ ចំពោះព្រះអង្គ ទោះ ជាស្វាមីក្ដី ភរិយាក្ដី ឬអ្នកណាផ្សេងទៀតក្ដី មិនត្រូវបំបាក់បំបែកគូស្រករ ដែលព្រះជាម្ចាស់បានផ្សំផ្គុំទៅ

### ថ្ងៃអាទិត្យទី២៨ ក្នុងរដូវធម្មតា (ថ្ងៃទី១១ ខែតុលា ឆ្នាំ២០០៩) *ម៉ាកុស ១០,១៧-៣០*

សប្ដាហ៍នេះមានន័យថា ថ្ងៃទី១១ ដល់១៨ ខែតុលា ជាសប្ដាហ៍សកលដើម្បីអង្វរព្រះជាម្ចាស់ សូមចាត់ បេសកជននាំមនុស្សលោកឱ្យស្គាល់ព្រះអង្គ។ នៅក្នុងព្រះបន្ទូលព្រះអង្គនៅថ្ងៃនេះ បានរៀ-បរាប់ពីបុរស ម្នាក់ដែលស្វែងរកព្រះអង្គយ៉ាងស្មោះ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ក៏គាត់មានអារម្មណ៍ថា នៅតែខ្វះអ្វី មួយ។ តាមពិតបុរសនេះជាជនសុចរិតមែនទែន ដែលគោរពវិន័យរបស់លោកម៉ូសេតាំងពីក្មេងមក។ ព្រះ យេស៊ូបានអញ្ជើញគាត់ ឱ្យលះបង់ចោលទ្រព្យសម្បត្តិទាំងអស់របស់គាត់ រួចទៅតាមព្រះអង្គ។ ប៉ុន្តែព្រះ បន្ទូលនេះក៏បណ្ដាលឱ្យគាត់ពិបាកសម្រេចចិត្ត។ រឿងនេះជួយយើងឱ្យយល់លើពីរចំណុច គឺទី១ ដរាបណា យើងមិនចេះលះបង់ទ្រព្យសម្បត្តិខ្លះៗ របស់យើងចែកដល់អ្នកក្រីក្រទេនោះ ដរាបនោះយើងមិនទាន់ជា សាវ័ករបស់ព្រះយេស៊ូពិតប្រាកដទេ។ ចំណុចទីពីរ

### ថ្ងៃអាទិត្យទី២៩ ក្នុងរដូវធម្មតា (ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៩) *ម៉ាកុស ១០,៣៥-៤៥*

ព្រះយេស៊ូ និងសាវ័ក១២នាក់ កំពុងធ្វើដំណើរឡើងទៅទីក្រុងយេរូសាឡឹម។ នៅពេលនោះ សាវ័កខ្លះ គិតច្រឡំថា ព្រះអង្គនឹងទម្លាក់ស្ដេចហេរ៉ូដ ហើយបណ្ដេញជនជាតិរ៉ូម៉ាំងពីស្រុកអ៊ីស្រាអែលភ្លាមៗ ដូច្នេះ សាវ័កទាំងនោះ សូមព្រះអង្គប្រទានតំណែងប្រកបដោយសិរីរុងរឿងឱ្យពួកគាត់នៅពេលព្រះអង្គនឹងគ្រង រាជ្យ។ ជាក់ស្ដែងគំនិតបែបនេះមិនមែនជាគំនិតរបស់ព្រះជាម្ចាស់ទេ នេះជាគំនិតរបស់មនុស្សសុទ្ធសាធ។ ដូច្នេះព្រះយេស៊ូពន្យល់ម្ដងទៀត អំពីព្រះសហគមន៍ថា ក្នុងចំណោមសាវ័កព្រះអង្គ

### ថ្ងៃអាទិត្យទី៣០ ក្នុងរដូវធម្មតា (ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០០៩) *យ៉ូហាន ១០,៤៦ខ-៥២*

រឿងលោកបារទីមេគឺជារឿងបុរសម្នាក់ដែលហ៊ានប្រកាសជំនឿអំពីព្រះយេស៊ូ ដោយទទួលការត្រាស់ ហៅពីព្រះអង្គផង ហើយដែលក្រោកឡើងចូលទីសង្គមមនុស្សធម្មតាវិញ។ គ្រាដើមដំបូង លោកបារទីមេ អង្គុយនៅក្បែរផ្លូវ មានន័យថា លោកនៅក្នុងចំណោមមនុស្សក្រៅសង្គម ឬគ្មានគេរាប់អាន។ បន្ទាប់មក លោកហ៊ានប្រកាសជំនឿពីឫទ្ធានុភាពរបស់ព្រះយេស៊ូ ដោយចិត្តអង់អាចមោះមុត ធ្វើឱ្យព្រះអង្គមានព្រះ ហឫទ័យស្រឡាញ់ និងត្រាស់ហៅគាត់។ ពេលនោះលោកបារទីមេក្រោកឡើងជានិមិត្តរូបនៃការរស់ឡើង វិញពីចំណោមមនុស្សស្លាប់ ដែលព្រះ យេស៊ូប្រទាន ឱ្យអស់អ្នកដែលជឿសង្ឃឹមលើព្រះអង្គ។ ជាទីបញ្ចប់ លោកបារទីមេមើលឃើញបាន

ព័ត៌មាន

## សាលាដុនបូស្កូ ខណ្ឌទួល-គោកបានជ្រើសរើសសិស្ស

កាលពីពេលថ្មីៗនេះ មានសិស្សានុសិស្សច្រើនរយនាក់ ដែលទើបតែបានប្រលងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ មកដាក់ពាក្យសុំប្រឡងចូលរៀននៅសាលាបណ្ដុះ-បណ្ដាលវិជ្ជាជីវៈ ដុនបូស្កូ នៅខណ្ឌទួលគោក រាជធានីភ្នំពេញ។

ទោះបីជាចំនួនសិស្សដែលបានដាក់ពាក្យសុំចូលរៀនមានចំនួនរាប់រយនាក់ក៏ដោយ តែសាលាបណ្ដុះបណ្ដាលដុនបូស្កូ នៅឆ្នាំនេះអាចទទួលសិស្សក្រីក្រ ឱ្យចូលរៀន ត្រឹមតែ ៥០នាក់ប៉ុណ្ណោះ។

ក្នុងចំណោមបេក្ខជន ២៥០នាក់ ដែលបានដាក់ពាក្យសុំចូលរៀនថ្នាក់ជំនាញកុំព្យូ-ទ័រ និងលេខាធិការរួចមក ពួកគេត្រូវតែឆ្លង កាត់ការប្រឡង សមត្ថភាព ការធ្វើសម្ភាស៍ ដោយផ្ទាល់ ហើយប្រាកដថា ជាសិស្សមកពីគ្រួសារក្រីក្រ។ ហើយលក្ខណៈវិនិច្ឆ័យមួយទៀតដើម្បីជ្រើសរើសសិស្សឱ្យចូលរៀនបាន គឺដរាបណាគេជាកូនស្រីច្បងក្នុងគ្រួសារ។

បងស្រីម៉ារី អេឡិណា មានប្រសាសន៍ថា កូនច្បងគឺជាក្ដីសង្ឃឹមក្នុងគ្រួសារ។ បេសក-កម្មរបស់យើង គឺជួយពួកគេឱ្យទទួលបាននូវការអប់រំមួយយ៉ាងល្អ និងត្រឹមត្រូវ



Photo : Keo Kagha

ក្លាយជាពលរដ្ឋល្អ

# “ជៀសពីគ្រឿងញៀន ដើម្បីការពារជីវិតអ្នក”

## លេខទូរសព្ទដែលត្រូវហៅ បន្ទាន់

*ករណីសង្ស័យគ្រុនផ្តាសាយថ្មី A/H1N1 :

១១៥ / ០១២ ៤៨៨ ៩៨១ / ០៨៩ ៦៦៩ ៥៦៧ ។

*មណ្ឌលកែប្រែអ្នកញៀនគ្រឿងញៀន :

០១២ ៨១២ ១១៧ / ០១៥ ៨៩៣ ៩៩៩ ។

*រថយន្តសង្គ្រោះបន្ទាន់ :

-ភ្នំពេញ ០២៣ ៧២៤ ៨៩១ ។ -សៀមរាប ០៦៣ ៧៦១ ១១៩ ។

*មជ្ឈមណ្ឌលផ្តល់ឈាម :

០២៣ ២១៥ ៩៤៩ ។

## ល្បែងកំសាន្ត

**ចំនុចខុស**

ចូរស្វែងរកចំនុចខុសគ្នា ចំនួន ៧ នៅលើរូប ទាំងពីរខាងក្រោម !



Photo : DR

## ការងារប្រចាំខែ

- ពេញ១ខែតុលា : ព្រះសហគមន៍កំពង់សោម រៀបចំកម្មវិធីអធិដ្ឋានផ្តាំតាមផ្ទះនីមួយៗ។
- ថ្ងៃទី០១ តុលា : ពិធីសម្ពោធសាលាមត្តេយ្យ សន្តប៉ូល កោះស្លា ដែលរៀបចំធ្វើឡើងនៅព្រះសហគមន៍កាតូលិកកំពត។
- ថ្ងៃទី០៣ តុលា : ប្រជុំគណៈកម្មការរបស់មណ្ឌលសកម្មភាពសន្តយ៉ូសែបភ្នំពេញ (មានទាំងអស់ ៩ព្រះសហគមន៍) រៀបចំធ្វើឡើងនៅព្រះសហគមន៍សន្តយ៉ូសែប (ផ្សារតូច)។
- ថ្ងៃទី០៤ តុលា : ពិធីរំឭកខួបគម្រប់ ២៨ឆ្នាំនៃព្រះវិហារព្រះក្សត្រីនៃសន្តិភាព នៅឃុំអរិយក្សត្រ ស្រុកល្វាឯម ខេត្តកណ្តាល។
- ថ្ងៃទី០៤ តុលា : ចាប់ផ្តើមបង្រៀនអប់រំជំនឿឡើងវិញនៅព្រះសហគមន៍ផ្សារតូច។
- ថ្ងៃទី០៤ តុលា : ប្រជុំគ្រូអប់រំជំនឿនៅព្រះសហគមន៍កាតូលិកព្រះកុមារយេស៊ូបឹងទំពុន រាជធានីភ្នំពេញ។
- ថ្ងៃទី០៩ តុលា : អភិបូជាពិសេសសម្រាប់និស្សិតបើកបវេសនកាលឆ្នាំសិក្សាថ្មី រៀបចំធ្វើឡើងនៅព្រះសហគមន៍កំពង់ចាម។
- ថ្ងៃទី១០-១១ តុលា : ប្រជុំបូកសរុប និងវាយតម្លៃចំពោះអង្គសន្និបាតយុវជនភូមិភាគភ្នំពេញរបស់គណៈកម្មការក្រុមយុវជន។
- ថ្ងៃទី១១ តុលា : ពិធីបើកវេសនកាលថ្មីនៅសាលាមត្តេយ្យនៅព្រះសហគមន៍កាតូលិកព្រះកុមារយេស៊ូ បឹងទំពុន រាជធានីភ្នំពេញ។
- ថ្ងៃទី១២-១៣ តុលា : ពិធីជំហានទី១ សម្រាប់មនុស្សចាស់២២នាក់ រៀបចំធ្វើឡើងនៅព្រះសហគមន៍ព្រែកទាល់ខេត្តសៀមរាប។
- ថ្ងៃទី១៥ តុលា : ការចាប់ផ្តើមកម្មវិធីបង្រៀនថ្នាក់ជាងទងនៅព្រះសហគមន៍កាតូលិកព្រះកុមាយេស៊ូបឹងទំពុន រាជធានីភ្នំពេញ។
- ថ្ងៃទី១៩-២៣ តុលា : សិក្ខាសាលាស្ពានសន្តិភាពរៀបចំនៅព្រះសហគមន៍កំពង់ចាម។
- ថ្ងៃទី២២-២៣ តុលា : ប្រជុំប្រចាំភូមិភាគបាត់ដំបងរៀបចំនៅព្រះសហគមន៍សៀមរាប។
- ថ្ងៃទី២៧ តុលា : ប្រជុំបូជាចារ្យភូមិភាគភ្នំពេញ រៀបចំធ្វើឡើងនៅនិវេសនដ្ឋានលោកអភិបាលអេមីល ដេតម្ប៊ូ។
- ថ្ងៃទី២៨ តុលា : ប្រជុំទីប្រឹក្សាភូមិភាគសម្រាប់ព្រះសហគមន៍កំពង់ចាម។
- ថ្ងៃទី២៩-៣០ តុលា : ប្រជុំគណៈកម្មការអន្តរភូមិភាគដើម្បីរៀបចំសៀវភៅអភិបូជា។